ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសិក្សាលម្អិតសម្រាប់

# ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម
(បរិញ្ញាបត្រ+២)

# មុខវិជ្ជាជម្រើស

វិទ្យាស្ថានជាតិអប់រំ

មេសា ២០២២

# មុខកថា

និន្នាការអប់រំសកល និងតំបន់ នាសតវត្សរ៍ទី២១ មានការប្រែប្រួលដោយសារការវិវត្តនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក៏ដូចជាតម្រូវការជាក់ស្តែងរបស់សង្គមជាតិ។ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ទី៤ ផ្តោតសំខាន់លើការអប់រំប្រកបដោយគុណភាព ដែលប្រទេសនីមួយៗត្រូវតែសម្រេចឱ្យបានត្រឹមឆ្នាំ២០៣០។

រាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលកំណត់ **ការអភិវឌ្ឍធនធានមនុស្ស** ជាអាទិភាពទីមួយ។ គោលដៅចម្បងរបស់រាជរដ្ឋាភិបាលគឺការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព តាមរយៈការបណ្តុះបណ្តាលមនុស្ស ឱ្យក្លាយទៅជាពលរដ្ឋពេញលេញដែលមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ។

ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យនេះ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ស៊ីជម្រៅលើគ្រប់អនុវិស័យ ក្នុងនោះការអភិវឌ្ឍកម្មវិធីសិក្សា គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពអប់រំនៅកម្ពុជា។ ឈរលើស្មារតីនេះ វិទ្យាស្ថានជាតិអប់រំ បានបង្កើតគណៈកម្មការកែលម្អកម្មវិធីបណ្តុះបណ្តាលនៅគ្រប់មុខវិជ្ជាសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) ដោយមានការសហការជាមួយភាគីពាក់ព័ន្ធដូចជាអង្គការខេប(KAPE) សាកលវិទ្យាល័យភូមិន្ទភ្នំពេញ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

កម្មវិធីបណ្តុះបណ្តាលលម្អិតសម្រាប់ការបណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តម(បរិញ្ញាបត្រ+២)នេះ ត្រូវបានរៀបចំជា៥ផ្នែក គឺមុខវិជ្ជារួមនៃឯកទេស មុខវិជ្ជាស្នូលនៃឯកទេស និងមុខវិជ្ជាជម្រើស។ នៅក្នុងឯកសារនេះមានវត្ថុបំណងរួម ខ្លឹមសារមេរៀន លទ្ធផលសិក្សារំពឹងទុក និងចំនួនក្រេឌីតសិក្សាតាមលំដាប់លំដោយ។ គរុនិស្សិតនឹងទទួលបានការបណ្តុះបណ្តាលប្រកបដោយគុណភាព ដើម្បីធ្វើជាមូលដ្ឋានគ្រឹះសម្រាប់ការរៀន និងបង្រៀននៅតាមគ្រឹះស្ថានសិក្សារបស់ពួកគាត់នាពេលអនាគត។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា ឯកសារនេះនឹងបានជាប្រយោជន៍ដល់អ្នកអនុវត្ត ជាពិសេសគរុនិស្សិតដែលទទួលបានការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ដើម្បីយកវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ទៅអនុវត្តក្នុងការបង្រៀនប្រកបដោយគុណភាព ប្រសិទ្ធភាព និងជំរុញឱ្យការអប់រំនៅកម្ពុជាមានភាពជឿនលឿន ដូចប្រទេសនានាក្នុងតំបន់ និងសកលលោក។

ថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# អារម្ភកថា

ក្នុងការអភិវឌ្ឍប្រទេសជាតិ ធនធានមនុស្សជាកម្លាំងយ៉ាងសំខាន់ សម្រាប់ធ្វើឱ្យការអភិវឌ្ឍសង្គមជាតិទទួលបានជោគជ័យ។ គោលដៅចម្បងរបស់ផែនការអភិវឌ្ឍសង្គម សេដ្ឋកិច្ច គឺការរៀបចំប្រជាជនយើងឱ្យក្លាយទៅជាពលរដ្ឋពេញលេញ គឺជាពលរដ្ឋល្អ ពលរដ្ឋថ្លៃថ្នូរ និងពលករជំនាញ។ ការអប់រំជាយុទ្ធសាស្ត្រយ៉ាងសំខាន់ដើម្បីឈានទៅសម្រេចគោលដៅនេះឱ្យបានជោគជ័យ។

ដូចនេះ កំណែលម្អវិស័យអប់រំ ជាការធានានូវការលើកកម្ពស់គុណភាពអប់រំ ដែលជានិន្នាការរួមរបស់បណ្ដាប្រទេសក្នុងពិភពលោក។ ឯការអភិវឌ្ឍកម្មវិធីសិក្សាលម្អិត គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពអប់រំ។ ឈរលើស្មារតីនេះ វិទ្យាស្ថានជាតិអប់រំ បានបង្កើតគណៈកម្មការកែលម្អកម្មវិធីសិក្សាលម្អិត នៅគ្រប់មុខវិជ្ជាសម្រាប់ការបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២) ដោយមានការសហការជាមួយគ្រប់អ្នកពាក់ព័ន្ធ ដូចជាអង្គការខេប (KAPE) ជាដើម។

កម្មវិធីសិក្សាលម្អិតសម្រាប់ការបណ្ដុះបណ្ដាលគរុនិស្សិតកម្រិតឧត្តម(បរិញ្ញាបត្រ+២)នេះ ត្រូវបានរៀបចំឡើងដោយផ្ដោតទៅលើមុខវិជ្ជាជម្រើស(សីលធម៌វិជ្ជាជីវៈគ្រូបង្រៀននិងរដ្ឋបាលអប់រំ សិល្បៈនិងវប្បធម៌ ប្រឹក្សាគរុកោសល្យ និន្នាការអប់រំនិងការអប់រំពលរដ្ឋពេញលេញ ភាសាបារាំង និងភាសាអង់គ្លេស) ដែលតម្រូវឱ្យមានការកែលម្អខ្លឹមសារ និងចំនួនក្រេឌីត។ នៅក្នុងឯកសារនេះ មានវត្ថុបំណងរួម ខ្លឹមសារមេរៀន លទ្ធផលសិក្សារំពឹងទុក និងចំនួនម៉ោងសិក្សាតាមលំដាប់លំដោយ។ គរុនិសិត្សនឹងទទួលបានលទ្ធផលសិក្សាទាំងនេះ ដើម្បីធ្វើជាមូលដ្ឋានគ្រឹះសម្រាប់ការបង្រៀននៅតាមគ្រឹះស្ថានសិក្សារបស់ពួកគាត់នាពេលអនាគត។

វិទ្យាស្ថានជាតិអប់រំ សង្ឃឹមទុកថា ឯកសារនេះនឹងបានជាប្រយោជន៍ដ៏សំខាន់ សម្រាប់អ្នកអនុវត្ត ជាពិសេសគរុនិស្សិតដែលទទួលបានការបណ្ដុះបណ្ដាលនៅវិទ្យាស្ថានជាតិអប់រំ ដើម្បីយកចំណេះដឹង និងជំនាញទៅអនុវត្តក្នុងការបង្រៀន ប្រកបដោយគុណភាព ប្រសិទ្ធភាពខ្ពស់ និងជំរុញឱ្យការអប់រំនៅកម្ពុជា មានការអភិវឌ្ឍដូចប្រទេសនានាក្នុងតំបន់ និងលើសកលលោក។

**គណៈកម្មការរៀបចំកម្មវិធីសិក្សាលម្អិត**

I- **គណៈកម្មការគ្រប់គ្រង**

១- ឯកឧត្តមបណ្ឌិត ឌី ខាំបូលី ២- ឯកឧត្តម សៀង សុវណ្ណា ៣- លោកបណ្ឌិត ឈូក ច័ន្ទឆាយ៉ា
៤- លោក ឌី បុណ្ណា ៥- លោកបណ្ឌិត នូវ វីរ៉ា ៦- លោកស្រី ប៊ុន សុផានី
៧- លោក ថៃ ហេង

II- **គណៈកម្មការនិពន្ធ និងរៀបរៀង**

**១- សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងរដ្ឋបាលអប់រំ**

១- លោក ឡេង បូរី ២- លោកស្រី អ៊ុំ សោភ័ណ្ឌ ៣- កញ្ញា សៀង សុជីវី
៤- លោក លុយ អោក ៥- លោក ចេង ថុន ៦- លោក ឆេង សារុន
៧- លោក សេង ឡាង

**២- សិល្បៈ និងវប្បធម៌**

១- លោកស្រី វ៉ា ចំណាន ២- លោកស្រី ណម ណារ័ត្ន ៣- លោកស្រី អ៊ុំ សុចិន្តា
៤- លោកស្រី តែ ស្រីសោភ័ណ្ឌ ៥- លោក ទេព ណម ៦- លោក សួន ចាន់ណា
៧- លោកស្រី ធុក ផល្លីនី

**៣- ប្រឹក្សាគរុកោសល្យ**

១- លោក ដាង ចាន់ណាក់ ២- លោកស្រី ជា ចាន់ប៉ុណ្ណា ៣- លោក ម៉ូត ណារិន
៤- កញ្ញា ឆែម គឹមសែន ៥- លោកស្រី ទៀប ចន្ទវត្តី

**៤- និន្នាការអប់រំ និងការអប់រំពលរដ្ឋពេញលេញ**

១- លោកបណ្ឌិត នូវ វីរ៉ា ២- លោកបណ្ឌិត ឈាង សង្វាត ៣- លោកបណ្ឌិត នី រដ្ឋា
៤- លោកបណ្ឌិត ម៉ម ចាន់សៀន

**៥- ភាសាបារាំង**

១- លោកស្រី ងួន ច័ន្ទលក្ខិណា ២- លោកស្រី ម៉ម ចំប៉ី ៣- កញ្ញា ភាព សុខនី
៤- លោក លឹម វ៉ាន់

**៦- ភាសាអង់គ្លេស**

១- លោក កែ ហុកស៊្រុន ២- លោក សេង វ៉ា ៣- លោក អៀម វ៉ោហា
៤- លោកស្រី ជឹម វុឌ្ឍានី ៥- លោក លាង តុលា ៦- លោក ប្រាជ្ញ ច័ន្ទសុខា

III- **គណៈកម្មការត្រួតពិនិត្យ កែលម្អ និងចងក្រងសៀវភៅ**

១- គ្រូឧទ្ទេសសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងរដ្ឋបាលអប់រំ
២- គ្រូឧទ្ទេសសិល្បៈ និងវប្បធម៌
៣- គ្រូឧទ្ទេសប្រឹក្សាគរុកោសល្យ
៤- គ្រូឧទ្ទេសនិន្នាការអប់រំ និងការអប់រំពលរដ្ឋពេញលេញ
៥- គ្រូឧទ្ទេសភាសាបារាំង
៦- គ្រូឧទ្ទេសភាសាអង់គ្លេស
៧- លោក ម៉ៅ សារឿន ៨- លោក គឹម លាង ៩- លោក ចេង ថុន
១០- លោកបណ្ឌិត អាន វ៉ូប្រាវ ១១- លោក អ៊ុក ញ៉ាល់ ១២- លោក អ៊ូ វណ្ណី
១៣- លោក សេង ឡាង ១៤- លោកស្រីបណ្ឌិត ឡឹយ សុគា ១៥- កញ្ញា ឆែម គឹមសែន
១៦- លោក ប៊ុនលី ម៉ារឌី ១៧- លោក ម៉ូត ណារិន ១៨- តំណាងអង្គការខេប(KAPE)

# មាតិកា

បុព្វកថា...................................................................................................i
អារម្ភកថា ...................................................................................................ii
គណៈកម្មការ ...................................................................................................iii
មាតិកា ...................................................................................................iv
ទស្សនវិជ្ជាអប់រំ ................................................................................................... ១
ចិត្តវិទ្យា ...................................................................................................៩
គរុកោសល្យ...................................................................................................១៧
ស្រាវជ្រាវអប់រំ...................................................................................................២៣
បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀននិងរៀន...................................................៣៣
វង្វាយតម្លៃលទ្ធផលសិក្សា ...................................................................................................៤៤

# សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន

## ១- សេចក្តីផ្តើម

គ្រូបង្រៀនគឺជាធនធានដ៏សំខាន់ក្នុងការកសាងធនធានមនុស្សសម្រាប់អភិវឌ្ឍន៍ប្រទេស។ សីលធម៌វិជ្ជាជីវៈគ្រូបង្រៀនគឺជាមុខវិជ្ជាដែលមិនអាចខ្វះបាន ដើម្បីឱ្យការបំពេញភារកិច្ចរបស់គ្រូប្រកបដោយប្រសិទ្ធិភាព មានវិជ្ជាជីវៈពិតប្រាកដ។

## ២- គោលបំណង

មេរៀននេះ មានគោលបំណងបណ្តុះការយល់ដឹងដល់អ្នកសិក្សាអំពី ការកសាងសមត្ថភាពគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ឈរលើស្មារតីទឹកចិត្តស្រឡាញ់វិជ្ជាជីវៈ គំនិតផ្តួចផ្តើម និងប្រកបដោយភាពច្នៃប្រឌិត។ ដើម្បីឆ្លើយតបនឹងបញ្ហាខាងលើ ការអប់រំការបណ្តុះបណ្តាលធនធានមនុស្ស ត្រូវផ្តោតលើតម្រូវការរបស់អ្នកសិក្សា តម្រូវការសង្គម និងទីផ្សារការងារ ស្របតាមចក្ខុវិស័យកំណែទម្រង់វិស័យអប់រំនៅកម្ពុជា។ យើងខ្ញុំសង្ឃឹមថា ឯកសារនេះនឹងបានរួមចំណែកក្នុងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ដើម្បីសម្រេចបានចក្ខុវិស័យ កំណែទម្រង់វិស័យអប់រំ។

ក្រោយពីសិក្សាខ្លឹមសារមេរៀននេះចប់គរុនិស្សិត គរុសិស្ស ទទួលបាន ចេះច្បាស់ទ្រឹស្តី ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ប្រែក្លាយខ្លួន ជាគ្រូបង្រៀនដែលមានវិជ្ជាជីវៈច្បាស់លាស់ មានមនសិការការងារ មានការទទួលខុសត្រូវ ជាគ្រូបង្រៀនប្រកបដោយគុណភាព ប្រសិទ្ធភាព លើរបវិជ្ជា ជីវៈក្នុងបេសកកម្មដ៏ឧត្តុងឧត្តម។ស្រលាញ់ចូលចិត្តការសិក្សា និងមានមនសិការស្មោះត្រង់ចំពោះជាតិ មាតុភូមិ ចង់បានឃើញពលរដ្ឋរបស់ខ្លួនមានទំនួលខុសត្រូវស្រលាញ់ប្រយោជន៍រួម។ ផ្សារភ្ជាប់សីលធម៌វិជ្ជាជីវៈទៅនឹងសកម្មភាពប្រចាំថ្ងៃរបស់គ្រូបង្រៀន។

### ក- វិជ្ជាសម្បទា

- បកស្រាយកត្តាសំខាន់ៗរបស់ទ្រឹស្តីសីលធម៌វិជ្ជជីវៈគ្រូបង្រៀន
- ប្រើប្រាស់ចំណេះដឹងថ្មី ៗដើម្បីពន្យល់ណែនាំសិស្សឱ្យដោះស្រាយបញ្ហាដោយខ្លួនឯង
- បង្ហាត់បង្រៀនទ្រឹស្តីច្បាស់លាស់ និងយកទៅអនុវត្តប្រកបដោយប្រសិទ្ធិភាពខ្ពស់ ដោយផ្អែកលើមូលដ្ឋានទ្រឹស្តី ប្រែក្លាយទៅជាការជាក់ស្តែងស្របតាមសរសេស្តមនៃការអប់រំ
- មានគំនិតច្នៃប្រឌិតក្នុងការបង្រៀន និងសិក្សាស្រាវជ្រាវបន្ថែមអំពីការវិវត្តថ្មីៗដល់សិស្សយក
- រៀបរាប់ពីខ្លឹមសារនៃមុខវិជ្ជាសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនឲ្យបានច្បាស់។

### ខ- បំណិនសម្បទា

- ស្គាល់ពីតួនាទី និងភារកិច្ច មុខរបរអាជីពជាគ្រូបង្រៀនបានច្បាស់លាស់
- មានស្មារតីសាមគ្គីភាព ជាអ្នកគ្រប់គ្រង ជាអ្នកដឹកនាំ ជាឳពុកម្តាយទី២ និងមានការទទួលខុសត្រូវខ្ពស់លើការងារបង្រៀន និងការងារអប់រំសិស្សឱ្យបានល្អ
- ជំរុញ លើកទឹកចិត្តសិស្សឱ្យស្រលាញ់ការរៀនសូត្រ និងដឹងថាអនាគត់របស់ពួកគេទៅណា។

### គ- ចរិយាសម្បទា

- ជំរុញលើកទឹកចិត្តសិស្សឱ្យស្រលាញ់ការសិក្សារៀនសូត្រ និងដឹងថាអនាគត់របស់ពួកគេទៅណា
- ប្រើប្រាស់ចំណេះដឹងថ្មីៗ ដើម្បីពន្យល់ណែនាំសិស្សឱ្យដោះស្រាយបញ្ហាដោយខ្លួនឯង
- អប់រំសិស្សស្គាល់ពីតម្លៃការសិក្សា និងតម្លៃពលរដ្ឋជាទំពាំងស្នងឬស្សី
- បង្ហាត់បង្រៀនទ្រឹស្តីច្បាស់លាស់ និងយកទៅអនុវត្តប្រកបដោយប្រសិទ្ធិភាពខ្ពស់ ដោយផ្អែកលើមូលដ្ឋាន

ទ្រឹស្តី ប្រែក្លាយទៅជាការដាក់ស្តែងស្របតាមសរសៃស្តម្ភនៃការអប់រំ

- មានគំនិតច្នៃប្រឌិតក្នុងការបង្រៀន និងសិក្សាស្រាវជ្រាវបន្ថែមអំពីការវិវត្តថ្មីៗដល់សិស្ស

- ជំរុញដល់សិស្សឱ្យចេះស្រលាញ់ចូលចិត្តការសិក្សា និងមានមនសិការស្មោះត្រង់ចំពោះជាតិ មាតុភូមិ ចង់បានឃើញពលរដ្ឋរបស់ខ្លួនមានទំនួលខុសត្រូវ ស្រលាញ់ប្រយោជន៍រួម

- ផ្សារភ្ជាប់សីលធម៌វិជ្ជាជីវៈទៅនឹងសកម្មភាពប្រចាំថ្ងៃរបស់គ្រូបង្រៀន

- បណ្តុះគំនិតឱ្យចេះគោរពសីលធម៌វិជ្ជាជីវៈ វិន័យការងារ អនុវត្តស្តង់គ្រូបង្រៀន

- មានស្មារតីសាមគ្គីភាព ជាអ្នកគ្រប់គ្រង ជាអ្នកដឹកនាំ ជាឪពុកម្តាយទី២ និងមានការទទួលខុសត្រូវខ្ពស់ លើការងារបង្រៀន និងការងារអប់រំសិស្សឱ្យបានល្អ។

## ៣- គោលគំនិតសំខាន់ៗ

- បំពេញភារកិច្ចប្រកបដោយសីលធម៌វិជ្ជាជីវៈ
- បញ្ជាបពីខ្លឹមសារនៃបទបញ្ញត្តក្រមសីលធម៌វិជ្ជាជីវៈ
- បែងចែកច្បាស់លាស់រវាង ជីវភាពរស់នៅឯកជន និងវិជ្ជាជីវៈគ្រូបង្រៀន
- បង្កើនទំនាក់ទំនងល្អជាមួយមហាជន មាតាបីតាសិស្ស អាជ្ញាធរគ្រប់លំដាប់ថ្នាក់។

## ៤- របាយម៉ោង

របាយម៉ោងសិក្សា នៃមុខវិជ្ជាសីលធម៌វិជ្ជាជីវៈ ត្រូវបានបែងចែកដូចក្នុងតារាងខាងក្រោម៖

| **មុខវិជ្ជា** | **រយៈពេលសិក្សា** |
|---|---|
| សីលធម៌វិជ្ជាជីវៈ | **១ ក្រេឌីត ស្មើ ១៥ ម៉ោងសិក្សា** |

## ៥- ការណែនាំអនុវត្ត

ដើម្បីអនុវត្តការបង្រៀននលើមុខវិជ្ជានេះឱ្យបានជោគជ័យគ្រូបង្រៀនគប្បីត្រូវ៖

- ឱ្យតម្លៃ និងអនុវត្តតាមទ្រឹស្តីសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន
- មានស្មារតីស្រឡាញ់ពេញចិត្តមុខរបរគ្រូបង្រៀន
- ប្រែក្លាយទៅជាគ្រូបង្រៀនអាជីព និងប្រកបដោយសមត្ថភាពខ្ពស់
- ឱ្យគរុនិស្សិតក្តាប់បានពីចំណុចគន្លឹះសំខាន់ៗ នៃគោលបំណងមេរៀន
- សម្របសម្រួលសិស្សក្នុងការក្តាប់បាននូវខ្លឹមសារមេរៀន ដោយធ្វើការវិភាគស្ថានភាព និងការពិភាក្សារកដំណោះស្រាយ ដើម្បីទទួលបានទាំងចំណេះ ជំនាញ និងឥរិយាបថដែលសង្គមត្រូវការ។

## ៦- ការវាយតម្លៃ

ការវាយតម្លៃ គឺជាចំណុចសំខាន់ក្នុងការវាស់ស្ទង់ពីអ្វីដែលអ្នកសិក្សាទទួលបានធៀបទៅនឹងវត្ថុបំណង នៃមេរៀន ឬចំណុចអប្បរមានៃចំណេះរបស់គរុនិស្សិតដែលគួរទទួលបានបន្ទាប់ពីបានបញ្ចប់ចំណុចនៃការ សិក្សានីមួយៗ និងបញ្ចប់មុខវិជ្ជា។ ការវាយតម្លៃទាំងនោះត្រូវរួមមាន៖

- សំណួរផ្ទាល់មាត់
- កិច្ចការផ្ទះ
- កិច្ចការក្រុម
- ការឡើងធ្វើបទបង្ហាញ

- ការសួរសំណួរ ការពិភាក្សា ការប្រឡង និងការធ្វើគម្រោងស្រាវជ្រាវជាដើម។

**៧- តារាងកម្មវិធីសិក្សាលម្អិត**

| **ខ្លឹមសារ** | **លទ្ធផលសិក្សា** | **ម៉ោង** |
|---|---|---|
| **មេរៀនទី១៖ ទ្រឹស្តីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន**<br>១.១- ទីតាំងរបស់គ្រូបង្រៀន<br>១.២- សីលធម៌វិជ្ជាជីវៈ | **វិជ្ជាសម្បទា**<br>ដឹង និងស្គាល់ច្បាស់ថាវិជ្ជាជីវៈគ្រូបង្រៀនជាមុខរបរដែលមិនមែនអ្នកណាក៏អាចធ្វើបានទេ<br>**បំណិនសម្បទា**<br>ដឹងច្បាស់ពីទីតាំង និងកម្មវត្ថុដែលត្រូវប្រត្តិបតិ<br>**ចរិយាសម្បទា**<br>បណ្តុះស្មារតីឱ្យស្រឡាញ់ មុខរបរ មានមនសិការ ពេញចិត្តនឹងការងារ | ១ម៉៣០ន |
| **មេរៀនទី២៖ គុណសម្បត្តិគ្រូបង្រៀន**<br>២.១- គុណសម្បត្តិគ្រូ បង្រៀន<br>២.២- គុណសម្បត្តិសីលធម៌<br>២.៣- គុណសម្បត្តិផ្នែកបញ្ញា | **វិជ្ជាសម្បទា**<br>- បកស្រាយពីគុណសម្បត្តិរបស់គ្រូបង្រៀន<br>- បង្ហាញពីសីលធម៌របស់គ្រូបង្រៀន<br>**បំណិនសម្បទា**<br>- ខិតខំសិក្សារៀនសូត្របន្តទៀត។<br>**ចរិយាសម្បទា**<br>- មានចិត្តអំណត់តស៊ូនិងការងារ។ | ៣ម៉០០ន |
| **មេរៀនទី៣៖ ជីវភាពឯកជនរបស់គ្រូ**<br>៣.១- ទស្សនទូទៅចំពោះគ្រូ<br>៣.២- តម្លៃរបស់គ្រូ | **វិជ្ជាសម្បទា**<br>- បង្ហាញអំពីតម្លៃរបស់គ្រូបង្រៀន។<br>**បំណិនសម្បទា**<br>- វិភាគពីទស្សនទូទៅចំពោះគ្រូបង្រៀន<br>**ចរិយាសម្បទា**<br>- ខិតខំការពារថែរក្សាតម្លៃរបស់គ្រូ។ | ១ម៉៣០ន |
| **មេរៀនទី៤៖ វប្បធម៌របស់គ្រូបង្រៀន**<br>៤.១- វប្បធម៌ជាគន្លឹះនៃការបង្រៀន និងការអប់រំ<br>៤.២- ធ្វើដូចម្តេចដើម្បីបណ្តុះវប្បធម៌? | **វិជ្ជាសម្បទា**<br>- ពន្យល់ពីសារសំខាន់ចាំបាច់វប្បធម៌។<br>**បំណិនសម្បទា**<br>- មានជំនាញច្បាស់លាស់ក្នុងការបង្រៀន<br>**ចរិយាសម្បទា**<br>- ខិតខំស្រាវជ្រាវរកអ្វីដែលថ្មី<br>- ចូលរួមបណ្តុះវប្បធម៌ដល់អ្នកជំនាន់ក្រោយ | ១ម៉៣០ន |

| | | |
|---|---|---|
| **មេរៀនទី៥៖ គរុនិស្សិត និង កម្មសិក្សា: អាកប្បកិរិយា ដែលគួរប្រតិបត្តិ**<br>៥.១- អាកប្បកិរិយាល្អ<br>៥.២- អាកប្បកិរិយាលមិនល្អ | **វិជ្ជាសម្បទា**<br>-បង្ហាញពីអាកប្បកិរិយាដែលគួរប្រតិបត្តិដល់គរុនិស្សិត<br>**បំណិនសម្បទា**<br>-វិភាគពីអាកប្បកិរិយាដែលគួរប្រតិបត្តិ និងមិនគួរប្រតិបត្តិ<br>**ចរិយាសម្បទា**<br>-អនុវត្តអាកប្បកិរិយាដែលគួរប្រតិបត្តិ<br>-វាយតម្លៃខ្ពស់ចំពោះអាកប្បកិរិយាដែលគួរប្រតិបត្តិ | ១ម៉ោ៣០ន |
| **មេរៀនទី៦៖ ទំនាក់ទំនងរបស់គ្រូបង្រៀនជាមួយមហាជន**<br>៦.១- ទំនាក់ទំនងជាមួយសិស្ស<br>៦.២- ទំនាក់ទំនងគ្រូ និងគ្រួសារសិស្ស<br>៦.៣- ទំនាក់ទំនងជាមួយប្រជាជនទូទៅ។ | **វិជ្ជាសម្បទា៖**<br>- បង្ហាញពីអំពីការទំនាក់ទំនងល្អ របស់គ្រូជាមួយសិស្ស គ្រួសារសិស្ស និងសហគមន៍។<br>**បំណិនសម្បទា៖**<br>- ធ្វើការទំនាក់ទំនង និងផ្តល់ព័ត៌មានដល់សិស្ស គ្រូ និងអាណាព្យាបាលសិស្ស។<br>**ចរិយាសម្បទា៖**<br>- ចូលរួមសកម្មក្នុងការងារទំនាក់ទំនង។ | ១ម៉ោ៣០ន |
| **មេរៀនទី៧៖ ករណីយកិច្ចរបស់គ្រូបង្រៀន**<br>៧.១- គ្រូត្រូវបំពេញភារកិច្ច៥យ៉ាង៖<br>- ការអប់រំបញ្ញា<br>- ការអប់រំកាយ<br>- ការអប់រំសីលធម៌<br>- ការអប់រំពលកម្ម និងកីឡា<br>-ការអប់រំសីល្បវិជ្ជៈ<br>៧.២- សមត្ថភាពបង្រៀន<br>៧.៣- មានយុត្តិធម៌ និងសមភាព<br>៧.៤- ត្រូវបង្កបរិយាកាសរីករាយក្នុងសាលារៀន | **វិជ្ជាសម្បទា៖**<br>-បកស្រាយអំពីការអប់រំប្រកបដោយចិរភាព ESD<br>-ពន្យល់ពីភារកិច្ចរបស់គ្រូបង្រៀនដែលត្រូវបំពេញ<br>**បំណិនសម្បទា៖**<br>- បង្រួបបង្រួមសិស្សមិនឱ្យមានការបែងចែកកម្រិត ជីវភាពលទ្ធភាព ឈរលើស្មារតីយុត្តិធម៌ ទទួលខុសត្រូវ។<br>**ចរិយាសម្បទា៖**<br>- បង្ហាញភាពជាគំរូល្អដល់សិស្ស។ | ៣ម៉ោ០០ន |

| | | |
|---|---|---|
| ៧.៥- ត្រូវយកចិត្តទុកដាក់ចំពោះ<br>សុខភាពសិស្ស<br>៧.៦- គំនិតច្នៃប្រឌិត ដើម្បី<br>ទទួលបានជោគជ័យ | | |
| **មេរៀនទី៨៖ គ្រូបង្រៀន និងការបង្កើតបរិយាកាសក្នុងថ្នាក់រៀន**<br>៨.១- បរិយាកាសល្អ<br>៨.២- បរិយាកាសមិនល្អ | **វិជ្ជាសម្បទា**<br>-បង្ហាញពីបរិយាកាសដែលត្រូវមាននៅក្នុងថ្នាក់<br>**បំណិនសម្បទា**<br>-មានជំនាញបង្កើតបរិយាកាសរីករាយ នៅក្នុងថ្នាក់រៀន<br>**ចរិយាសម្បទា**<br>-បង្កបរិយាកាសរីករាយទាំងក្នុងថ្នាក់ និងក្រៅថ្នាក់ | ១ម៉៣០ន |
| **សរុប** | **១ក្រេឌីត =១៥ម៉ោង** | |

## ៨- ឯកសារយោង


១- គោលនយោបាយអប់រំ ក្រសួងអប់រំ យុវជន និងកីឡា

២- ច្បាប់ស្តីពី កាអប់រំ, ក្រសួងអប់រំ យុវជន និងកីឡា

៣- ទ្រឹស្តីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន, វិទ្យាស្ថានជាតិអប់រំ, ២០០៦-២០០៧

៤- ស្តង់ដាគ្រូបង្រៀន

៥- ឯកសារនីតិកម្ម, ក្រសួងអប់រំ យុវជន និងកីឡា

# រដ្ឋបាលអប់រំ

## ១- សេចក្ដីផ្ដើម

រដ្ឋបាលសិក្សា សំដៅលើការងារគ្រប់គ្រងអប់រំ សាលារៀន ឬថ្នាក់រៀន។ ចំណែកលិខិតរដ្ឋបាល គឺជាគោលការណ៍ច្បាប់របស់ប្រទេសមួយបង្កើតឡើង ដើម្បីសម្រួលដល់ការប្រាស្រ័យទាក់ទងពីស្ថាប័នមួយ ទៅស្ថាប័នមួយ ពីបុគ្គលទៅអង្គភាព ពីស្ថាប័នមួយទៅបុគ្គលិកម្នាក់ ឬច្រើននាក់ ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ ដើម្បីឈានទៅសម្រេចការងារភារកិច្ចអ្វីមួយតាមវត្ថុបំណង។

លិខិតរដ្ឋបាល ជាលិខិតផ្លូវការរបស់រដ្ឋ ដែលមានរបៀបសរសេរទៅតាមទម្រង់មួយខុសប្លែកពីលិខិតឯកជន។ ក្នុងការគ្រប់គ្រងប្រទេស គ្រប់គ្រងស្ថាប័នរបស់រដ្ឋ ត្រូវប្រើប្រាស់លិខិស្នាមជាច្រើនសម្រាប់ទំនាក់ទំនងគ្នា ហើយរាល់ការទាក់ទងពីស្ថាប័នមួយ ទៅស្ថាប័នមួយទៀត មិនមានទម្រង់ដូចគ្នាទាំងអស់ទេ និងមានសណ្ឋានបែបបទខុសៗគ្នា ដែលមានកម្រិត ឬឋានានុក្រមខុសៗគ្នាដែរ។

ចំណុចសំខាន់ដែលត្រូវយកចិត្តទុកដាក់ចំពោះលិខិតរដ្ឋបាល គឺត្រូវសរសេរយ៉ាងណាឱ្យមានប្រសិទ្ធភាពពោលគឺសរសេរឱ្យបានងាយស្រួលស្ដាប់ ងាយយល់ ឱ្យបានច្បាស់ន័យសេចក្ដីខ្លី និងមានន័យគ្រប់គ្រាន់ចៀសវាងការរៀបរាប់វែងអន្លាយសារចុះសារឡើងមិនចំខ្លឹមសារ។ លិខិតរដ្ឋបាលនិយាយពីសាច់ការសុទ្ធសាធអស់សាច់ការចប់ត្រឹមនោះ។

បច្ចុប្បន្ននេះ លិខិតស្នាម របាយការណ៍ផ្សេងៗ និងការបញ្ចេញមតិយោបល់ជាលាយលក្ខណ៍អក្សរគឺជាព័ត៌មាន និងជាឧបករណ៍ធ្វើការងារដ៏មានប្រសិទ្ធភាពបំផុតក្នុងការគ្រប់គ្រងការិយាល័យ អង្គភាព ស្ថាប័នផ្សេងៗទាំងផ្នែកសាធារណៈ និងផ្នែកឯកជន។ ប្រភេទខ្លឹមសារ និងគំរូនៃលិខិតស្នាម និងរបាយការណ៍មានច្រើនប្រភេទអាស្រ័យទៅតាមមុខជំនាញក្នុងវិស័យនីមួយៗផងដែរ និងអាស្រ័យទៅតាមរបៀបជាទម្លាប់ធ្វើការងាររបស់ប្រទេសនីមួយៗផងដែរ។ ទោះបីមានការខុសគ្នាខ្លះៗក៏ដោយ បញ្ហាសំខាន់នៅត្រង់ថាតើខ្លឹមសារនៃលិខិត ឬរបាយការណ៍នោះមានន័យគ្រប់គ្រាន់ ច្បាស់លាស់ និងត្រឹមត្រូវសម្រាប់ឱ្យអ្នកទទួលអាចយល់ដឹងបាន អនុវត្តន៍បានដែរ ឬទេ? នេះជាបញ្ហាសំខាន់ និងជាកម្មវត្ថុនៃមេរៀននេះ ដែលជាឯកសារណែនាំជាមគ្គុសទ្ទេសក៍ ក្នុងការរៀបរៀងសរសេរលិខិតស្នាម និងរបាយការណ៍ផ្សេងៗផ្នែករដ្ឋបាល។

## ២- គោលបំណង

ក្រោយពីបានសិក្សាខ្លឹមសារមេរៀននេះចប់គរុនិស្សិតទទួលបាន ៖

### ក- វិជ្ជាសម្បទា

- ពន្យល់ពីគំរូ និងរបៀបរៀបចំសរសេរតាក់តែងលិខិតបទដ្ឋាននានាមាន លិខិតគតិយុត្តិ លិខិតរដ្ឋបាល និងលិខិតឯកជនបានច្បាស់លាស់ត្រឹមត្រូវ
- ប្រាប់បានពីការប្រើប្រាស់ពាក្យពេចន៍ និងឃ្លាឃ្លោង ដោយដោយគោរពតាមឋានានុក្រម ដឹងខ្ពស់ ដឹងទាប ក្នុងការសរសេរលិខិតស្នាម ដើម្បីធ្វើទំនាក់ទំនងការងារផ្សេងៗបានត្រឹមត្រូវ
- ប្រាប់បានពីរបៀបគ្រប់គ្រងរដ្ឋបាលតាមផ្នែកផ្សេងៗគ្នា ដូចជាការគ្រប់គ្រងថ្នាក់រៀន ការគ្រប់គ្រងសាលារៀន និងការងារគ្រប់គ្រងលើកិច្ចការផ្សេងៗទៀត ទៅតាមភារកិច្ចដែលទទួលបានសមហេតុសមផល។

### ខ- បំណិនសម្បទា

- សរសេរលិខិតស្នាមនានា ដើម្បីធ្វើទំនាក់ទំនង ក្នុងភារកិច្ចប្រចាំថ្ងៃ បានល្អតាមតម្រូវការ

- គ្រប់គ្រងការងារ ដោយប្រកាន់ខ្ជាប់ភាពជាអ្នកដឹកនាំល្អ ប្រកបដោយជោគជ័យ។

**គ- ចរិយាសម្បទា**

- ទំនាក់ទំនងរាល់កិច្ចការការងារ តាមរយៈលិខិតស្នាម ដោយគោរពឋានានុក្រមដឹងទាប ដឹងស្មើ ដឹងខ្ពស់បានល្អសមរម្យ

- ប្រកាន់នូវជំហរទន់ភ្លន់ ម៉ឺងម៉ាត់ក្នុងរាល់ការងារគ្រប់គ្រង និងដឹកនាំដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ជាប់ជានិច្ច។

## ៣-គោលគំនិតសំខាន់ៗ

- ផ្សារភ្ជាប់ជំនាញរដ្ឋបាលទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ និងវិជ្ជាជីវៈជាគ្រូបង្រៀន
- បណ្តុះគំនិតឱ្យចេះស្រឡាញ់ និងយកចិត្តទុកដាក់ទៅលើការងាររដ្ឋបាល
- យល់ និងចេះប្រើប្រាស់លិខិតរដ្ឋបាលទៅតាមប្រភេទលិខិតផ្សេងៗ។

## ៤-របាយម៉ោងសិក្សា

របាយម៉ោងសិក្សានៃមុខវិជ្ជារដ្ឋបាលសិក្សា ត្រូវបានបែងចែកដូចក្នុងតារាងខាងក្រោម ៖

| មុខវិជ្ជា | រយៈពេលសិក្សា |
|---|---|
| រដ្ឋបាលសិក្សា | **១ ក្រេឌីត ស្មើ ១៥ ម៉ោងសិក្សា** |

## ៥-ការណែនាំអនុវត្ត

ដើម្បីអនុវត្តន៍ការបង្រៀននូវនូវមុខវិជ្ជារដ្ឋបាលសិក្សាឱ្យទទួលបានជោគជ័យ គ្រូបង្រៀនគប្បី៖

- ឱ្យអ្នកសិក្សាក្តាប់បានពីចំណុចគន្លឹះសំខាន់ៗនៃមេរៀនតាមរយៈការប្រើគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការរៀន និងបង្រៀន ជំរុញការសិក្សាតាមរយៈសកម្មភាព ហ្វឹកហាត់ជាបុគ្គល ជាដៃគូ ជាក្រុម និងការសម្តែង ឬការស្រាវជ្រាវផ្សេងៗ។

- សម្របសម្រួលសិស្សក្នុងការក្តាប់បាននូវខ្លឹមសារមេរៀន ដោយធ្វើការសម្តែងចេញនូវទម្រង់លិខិតរដ្ឋបាលផ្សេងៗ និងការពិភាក្សារកដំណោះស្រាយ ដើម្បីទទួលបានចំណេះដឹង ជំនាញ និងឥរិយាបថដែលសង្គមត្រូវការ។

## ៦-វាយតម្លៃ

ការវាយតម្លៃ គឺជាចំណុចដ៏សំខាន់ក្នុងការវាស់ស្ទង់ពីអ្វីដែលអ្នកសិក្សាទទួលបាន ធៀបទៅនឹងវត្ថុបំណងនៃមេរៀន ឬចំណុចអប្បរមានៃចំណេះដឹងរបស់អ្នកសិក្សាដែលគួរទទួលបានបន្ទាប់ពីបានបញ្ចប់ចំណុចនៃការសិក្សានីមួយៗ និងបញ្ចប់មុខវិជ្ជា។ ការវាយតម្លៃរួមមាន ៖

- សំណួរផ្ទាល់មាត់
- សំណួរសរសេរ
- កិច្ចការផ្ទះ
- កិច្ចការក្រុម
- ការឡើងធ្វើបទបង្ហាញ
- ការប្រឡង និងធ្វើគម្រោងស្រាវជ្រាវជាដើម។

## ៧-តារាងកម្មវិធីលម្អិត

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **មេរៀនទី១ : រដ្ឋបាលអប់រំ**<br>១.អត្ថន័យនៃពាក្យរដ្ឋបាល នីតិរដ្ឋបាល វិទ្យាសាស្ត្ររដ្ឋបាល<br>២.ពាក្យរដ្ឋបាល<br>៣.គោលដៅរបស់រាជការ<br>៤.មធ្យោបាយរបស់រាជការ<br>៥.អំពើរបស់រាជការ និងវិធានគតិយុត្ត | • **វិជ្ជាសម្បទា**<br>- ពន្យល់ន័យនៃពាក្យរដ្ឋបាល ស្គាល់តួនាទីរាជការនិងវិធានគតិយុត្តិ<br>• **បំណិនសម្បទា**<br>- ចេះរកកើតនៃពាក្យរដ្ឋបាល និងតួនាទីរាជការ<br>• **ចរិយាសមប្បទា**<br>- ចូលចិត្ត និងឱ្យតម្លៃលើការងាររដ្ឋបាល | **៩០នាទី** |
| **មេរៀនទី២ : លិខិតរដ្ឋបាល**<br>១.និយមន័យ<br>២.ប្រភេទលិខិតរដ្ឋបាល<br>៣.ទម្រង់លិខិតរដ្ឋបាល<br>៤.ការពន្យល់អំពីទម្រង់លិខិតរដ្ឋបាល | • **វិជ្ជាសម្បទា**<br>- ពន្យល់បាន សរសេរបានពីទម្រង់លិខិតរដ្ឋបាល<br>• **បំណិនសម្បទា**<br>- ចេះសរសេរបានពីទម្រង់លិខិតរដ្ឋបាល<br>• **ចរិយាសមប្បទា**<br>- មានស្មារតីទទួលខុសត្រូវ ក្នុងការសរសេរទៅតាមឋានានុក្រម | **១៨០ នាទី** |
| **មេរៀនទី៣ : ការប្រើពាក្យពេចន៍**<br>ក.ការប្រើប្រាស់ពាក្យពេចន៍<br>ខ.គំរូលិខិតរដ្ឋបាលផ្លូវការ | • **វិជ្ជាសម្បទា**<br>- ពន្យល់បានពីការប្រើប្រាស់ពាក្យពេចន៍ និងលិខិតរដ្ឋបាល<br>• **បំណិនសម្បទា**<br>- ចេះពាក្យពេចន៍បានសរសេរបានពីលិខិតរដ្ឋបាល<br>• **ចរិយាសមប្បទា**<br>- មានស្មារតីទទួលខុសត្រូវក្នុងការសរសេរលិខិតដោយចេះប្រើប្រាស់ពាក្យពេចន៍ទៅតាមទម្រង់លិខិតផ្សេងៗ។ | ៩០នាទី |
| **មេរៀនទី៤: លិខិតអញ្ជើញ កំណត់ហេតុ របាយការណ៍ ឧទ្ទេសនាម បង្គាប់ការ វិញ្ញាបន បត្ររដ្ឋបាល និងបង្ហាញរឿង**<br>ក.លិខិតអញ្ជើញ និងកំណត់ហេតុ<br>ខ.របាយការណ៍ | • **វិជ្ជាសម្បទា**<br>- ពន្យល់ពីទម្រង់លិខិត កំណត់ហេតុ របាយ-ការណ៍ ឧទ្ទេសនាម បង្គាប់ការ វិញ្ញាបនបត្រ និងបង្ហាញរឿងបានត្រឹមត្រូវ។<br>• **បំណិនសម្បទា**<br>- ចេះសរសេរទម្រង់លិខិត កំណត់ហេតុ របាយ | ក.៩០ នាទី<br>ខ.៩០ |

| | | |
|---|---|---|
| គ. លិខិតឧទ្ទេសនាម បង្គាប់ការ<br>ឃ.វិញ្ញាបនបត្ររដ្ឋបាល និងបង្ហាញរឿង | ការណ៍ ឧទ្ទេសនាម បង្គាប់ការ វិញ្ញាបនបត្រ និងបង្ហាញរឿងបានត្រឹមត្រូវល្អ។<br>**• ចរិយាសម្បទា**<br>- មានស្មារតីទទួលខុសត្រូវ ក្នុងការសរសេរដោយចេះប្រើប្រាស់ពាក្យពេចន៍ទៅតាមទម្រង់លិខិតផ្សេងៗ។ | នាទី<br><br>គ.៩០ នាទី<br><br>ឃ.៩០ នាទី |
| **មេរៀនទី៥ : ទ្រឹស្តីនៃការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ**<br>ក.ទ្រឹស្តីនៃការគ្រប់គ្រង<br>ខ.ភាពជាអ្នកដឹកនាំ | **•វិជ្ជាសម្បទា**<br>- ពន្យល់បកស្រាយបានពីអត្ថន័យទ្រឹស្តីគ្រប់គ្រង គោលការណ៍ដឹកនាំ ស្គាល់ពីមុខងារ និងវដ្តនៃការគ្រប់គ្រង ក៏ដូចភាពជាអ្នកដឹកនាំបាន។<br>**•បំណិនសម្បទា**<br>- ចេះគ្រប់គ្រង និងដឹកនាំថ្នាក់រៀន សាលារៀនរបស់ខ្លួនបានទៅតាមគោលការណ៍ មុខងារនៃទ្រឹស្តីគ្រប់គ្រង និងភាពជាអ្នកដឹកនាំបាន។<br>**•ចរិយាសម្បទា**<br>- មានស្មារតីទទួលខុសត្រូវក្នុងការគ្រប់គ្រងដោយគោរពទៅតាមគោលការណ៍។ | ក.៩០ នាទី<br>ខ.៩០ នាទី |

## ៨- ឯកសារយោង


១- ក្រសួងអប់រំ យុវជន និងកីឡា *ការតាក់តែងលិខិតរដ្ឋបាល* បោះពុម្ពលើកទី១ ឆ្នាំ២០១៨

២- ពត សុត *នីតិរដ្ឋបាល អប់រំ* បោះពុម្ពលើកទី១ ឆ្នាំ២០១៤

៣- ទីស្តីការគណៈរដ្ឋមន្ត្រី *រាជកិច្ច* បោះពុម្ពលើកទី១ ឆ្នាំ២០១៣

៤- វិទ្យាស្ថានជាតិអប់រំ *រដ្ឋបាល សិក្សា* បោះពុម្ពលើកទី១ ឆ្នាំ២០១២

៥- ក្រសួងអប់រំ យុវជន និងកីឡា *ការគ្រប់គ្រង រដ្ឋបាល* បោះពុម្ពលើកទី២ ឆ្នាំ២០០៩

៦- ទីស្តីការគណៈរដ្ឋមន្ត្រី *លិខិតបទដ្ឋានគតិយុត្តិ* បោះពុម្ពលើកទី១ ឆ្នាំ២០០៧

៧- វិទ្យាស្ថានជាតិអប់រំ *រដ្ឋបាល សិក្សា* បោះពុម្ពលើកទី១ ឆ្នាំ២០០៧

៨- បណ្ឌិត ធ សោ *រដ្ឋបាល អប់រំ* បោះពុម្ពលើកទី១ ឆ្នាំ២០០៦

៩- មាឃ សារី *រដ្ឋបាល អប់រំ* បោះពុម្ពលើកទី១ ឆ្នាំ២០០៦

១០- ក្រសួងអប់រំ យុវជន និងកីឡា *ការគ្រប់គ្រងរដ្ឋបាល* បោះពុម្ពលើកទី១ ឆ្នាំ២០០២

១១- អ៊ុយ ស៊ីម *ចំណេះដឹងការងាររដ្ឋបាល* បោះពុម្ពលើកទី១ ឆ្នាំ១៩៩៨

# សិល្បៈ

## ១- សេចក្ដីផ្ដើម

សិល្បៈជាធាតុដ៏សំខាន់របស់វប្បធម៌ ឯវប្បធម៌ជាក្បាល ជាព្រលឹង ជាខួរ ជាប៉ុស្ដិ៍បញ្ញា របស់ជាតិ និងសង្គម។ បណ្ដាប្រទេសមួយចំនួនស្គាល់ប្រាសាទអង្គរវត្តដែលជាស្នាដៃដ៏អស្ចារ្យរបស់បុព្វបុរសខ្មែរ របាំក្បាច់បុរាណដ៏ល្អវិចិត្រក្នុងខណៈពេលដែលគេមិនស្គាល់ប្រទេសកម្ពុជា។ យើងសឹងតែអាចវិនិច្ឆ័យបានថា កិត្តិនាមជាតិខ្មែរបានស្ថិតស្ថេរគង់វង្សរហូតដល់សព្វថ្ងៃមួយភាគធំដោយសារស្នាដៃសិល្បៈដែលមានដូចជា៖ ប្រាសាទបុរាណ សិល្បៈរបាំ ភ្លេង ចម្រៀង សៀក ភាពយន្ត ស្នាដៃសិប្បកម្ម និងការរចនា ផ្សេងៗជាដើម។

ដើម្បីរួមចំណែកលើកតម្កើង ផ្សព្វផ្សាយ និងថែរក្សាសិល្បៈខ្មែរ និងដើម្បីឱ្យនិស្សិតក៏ដូចជាកូនខ្មែរគ្រប់រូបបានយល់ដឹងពីតម្លៃសិល្បៈខ្មែរយើងខ្ញុំបានចងក្រងនូវកម្មវិធីសិក្សានេះឡើងដើម្បីដំណើរការក្នុងការបណ្ដុះបណ្ដាលគ្រូកម្រិតឧត្ដម(បរិញ្ញាបត្រ+២) មុខវិជ្ជាសិល្បៈដែលជាមុខវិជ្ជារួម នៅវិទ្យាស្ថានជាតិអប់រំ។

## ២- គោលបំណង

- យល់ដឹងអំពីតម្លៃនៃសិល្បៈបុរាណរបស់ខ្មែរ និងបន្តផ្សព្វផ្សាយចំណេះដឹងខាងសិល្បៈឱ្យកាន់តែទូលំទូលាយ
- ផ្សារភ្ជាប់ជំនាញសិល្បៈទៅនឹងជីវិតរស់នៅ និងវិជ្ជាជីវៈជាគ្រូបង្រៀន។

### ក- វិជ្ជាសម្បទា

- បកស្រាយបាននូវទ្រឹស្ដី និងចំណេះដឹងអំពីសិល្បៈទស្សនីយភាពមានដូចជា របាំ តន្ត្រី ចម្រៀង ល្ខោន ជាដើម។ល។
- ស្វែងយល់នូវក្បួនខ្នាត អត្តសញ្ញាណ និងពណ៌សម្បុរនៃសិល្បៈបុរាណខ្មែរ។

### ខ- បំណិនសម្បទា

- អនុវត្តបាននូវសិល្បៈទស្សនីយភាពខ្មែរមួយចំនួន(ចម្រៀង របាំ ការសំដែង)
- បែងចែកបានពីតួនាទី និងសារសំខាន់នៅគ្រប់ទម្រង់សិល្បៈទស្សនីយភាពខ្មែរ
- វិភាគ វាយតម្លៃចំពោះគុណតម្លៃនៃសិល្បៈខ្មែរ
- រៀបរៀង និងច្នៃប្រឌិតទម្រង់សិល្បៈខ្លីៗមានដូចជា ល្ខោននយីកេ បាសាក់ ល្ខោននិយាយ ឬល្ខោនអប់រំខ្លីៗ។

### គ- ចរិយាសម្បទា

- ផ្លាស់ប្ដូរឥរិយាបថ និងបណ្ដុះទឹកចិត្តស្រលាញ់ ឱ្យតម្លៃទៅលើសិល្បៈវប្បធម៌ជាតិ
- ទាញបានសេចក្ដីសន្និដ្ឋាន និងយកមកអនុវត្តនៅក្នុងជីវិតប្រចាំថ្ងៃប្រកបដោយឥរិយាបថសុភាពរាបសា ទន់ភ្លន់ កាយសម្បទាមាំមួន និងមានគំនិតជាតិនិយម។

## ៣- គោលគំនិតសំខាន់ៗ:

- ផ្សារភ្ជាប់ជំនាញសិល្បៈទៅនឹងជីវិតរស់នៅ និងវិជ្ជាជីវៈជាគ្រូបង្រៀន
- យល់ដឹងអំពីតម្លៃសិល្បៈ វប្បធម៌ និងបណ្ដុះគំនិតស្រឡាញ់សិល្បៈវប្បធម៌ជាតិ។

## ៤- របាយម៉ោងសិក្សា

របាយម៉ោងសិក្សានៃមុខវិជ្ជាសិល្បៈ ត្រូវបានបែងចែកដូចក្នុងតារាងខាងក្រោម៖

| មុខវិជ្ជា | រយៈពេលសិក្សា |
|---|---|
| សិល្បៈ(សិល្បៈរួម) | **១ ក្រេឌីត ស្មើ ១៥ ម៉ោងសិក្សា** |

## ៥- ការណែនាំអនុវត្ត

ដើម្បីអនុវត្តការបង្រៀននូវមុខវិជ្ជាសិល្បៈនេះបានជោគជ័យ គ្រូបង្រៀនគប្បីត្រូវ៖

-ឱ្យអ្នកសិក្សាក្តាប់បានពីចំណុចគន្លឹះសំខាន់ៗនៃមេរៀនតាមរយៈការប្រើគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការរៀននិងបង្រៀន ជំរុញការសិក្សាតាមបែបសកម្មតាមរយៈការហ្វឹកហាត់ជាបុគ្គលជាដៃគូ ជាក្រុមនិងការសំដែង និងកិច្ចការស្រាវជ្រាវផ្សេងៗ។

-សម្របសម្រួលសិស្សក្នុងការក្តាប់បាននូវខ្លឹមសារមេរៀនដោយធ្វើការសំដែងចេញនូវទម្រង់សិល្បៈផ្សេងៗ និងការពិភាក្សារកដំណោះស្រាយ ដើម្បីទទួលបានចំណេះដឹង ជំនាញ និងឥរិយាបទ ដែលសង្គមត្រូវការ។

## ៦- វាយតម្លៃ

ការវាយតម្លៃគឺជាចំណុចដ៏សំខាន់ក្នុងការវាស់ស្ទង់ពីអ្វីដែលអ្នកសិក្សាទទួលបាន ធៀបទៅនឹងវត្ថុបំណងនៃមេរៀន ឬចំណុចអប្បបរមានៃចំណេះដឹងអ្នកសិក្សាដែលគួរទទួលបានបន្ទាប់ពីបញ្ចប់មុខវិជ្ជាសិល្បៈ។ ការវាយតម្លៃរួមមាន៖

- អនុវត្តសំដែងនូវទម្រង់សិល្បៈផ្សេងៗ
- កិច្ចការជាក្រុម
- ការសួរសំណួរពិភាក្សា
- ការធ្វើបទបង្ហាញ
- សំណួរផ្ទាល់មាត់។

## ៧- តារាងកម្មវិធីសិក្សាលម្អិត

| **ខ្លឹមសារ** | **លទ្ធផលរំពឹងទុក** | **ម៉ោង** |
|---|---|---|
| **មេរៀនទី១ សិល្បៈខ្មែរ**<br>១.១- ប្រភេទសិល្បៈ<br>១.២- សិល្បៈច្បង(ធំ)<br>១.៣- សិល្បៈបន្ទាប់បន្សំ(តូច)<br>១.៤- សិល្បៈទស្សនីយភាព<br>១.៥- សារៈសំខាន់ក្នុងការបណ្តុះគំនិតសិល្បៈ<br><br>-សំណួរពិភាក្សា | **វិជ្ជាសម្បទា ៖**<br>-កំណត់ពីនិយមន័យសិល្បៈ និងប្រភេទសិល្បៈខ្មែរគ្រប់ទម្រង់បានច្បាស់លាស់តាមរយៈខ្លឹមសារមេរៀន។<br>**បំណិនសម្បទា ៖**<br>-បកស្រាយបានពីទម្រង់សិល្បៈនីមួយៗបានត្រឹមត្រូវតាមរយៈការពិភាក្សា។<br>**ចរិយាសម្បទា ៖**<br>-មានចិត្តស្រឡាញ់សិល្បៈខ្មែរគ្រប់ទម្រង់ និងជួយថែ រក្សាការពារសិល្បៈបុរាណខ្មែរ។ | ០៣ម៉ោង ទ្រឹស្តី ០៦ម៉ោង អនុវត្ត |

| | | |
|---|---|---|
| **មេរៀនទី២ ភ្លេងជាតិ**<br>២.១- បទនគររាជ(គោរពទង់ជាតិ)<br>២.១.១- ប្រវត្តិបទនគររាជ<br>២.១.២- អត្ថបទបទនគររាជ<br>២.២- បទពង្សាវតារខ្មែរ<br>២.២.១- ប្រវត្តិបទពង្សាវតារខ្មែរ<br>២.២.២- អត្ថបទបទពង្សាវតារខ្មែរ<br><br>-សំណួរពិភាក្សា និងអនុវត្ត | **វិជ្ជាសម្បទា ៖**<br>- បង្ហាញពីប្រវត្តិ និងការវិវត្តបទនគររាជ(ភ្លេង ជាតិ) និងបទពង្សាវតារខ្មែរ កាន់តែច្បាស់ពីសារប្រយោជន៍នៃបទភ្លេងជាតិតាមរយៈអត្ថបទមេរៀន និងចម្រៀង។<br>**បំណិនសម្បទា ៖**<br>- អនុវត្តបច្ចេកទេសច្រៀងចម្រៀងបទនគររាជ (ភ្លេង ជាតិ)និងចម្រៀងពង្សាវតារខ្មែរបានត្រឹមត្រូវតាមបទ ភ្លេង ទំនុកច្រៀង និងចង្វាក់ភ្លេងជាក្រុម។<br>**ចរិយាសម្បទា ៖**<br>- គោរពស្រឡាញ់នូវជាតិ សាសនា ព្រះមហាក្សត្រ។ | ០៣ម៉ោងទ្រឹស្តី<br>០៦ ម៉ោងអនុវត្ត |
| **មេរៀនទី៣ របាំខ្មែរ**<br>៣.១- របាំព្រះរាជទ្រព្យ ឬរបាំក្បាច់បុរាណខ្មែរ<br>៣.១.១- អត្ថន័យក្បាច់ដៃ<br>៣.២- របាំប្រពៃណី<br>៣.៣- របាំប្រជាប្រិយ<br><br>-ដឹកនាំរៀបចំនូវទស្សនីយភាពរបាំ<br>-សំណួរពិភាក្សា និងអនុវត្ត | **វិជ្ជាសម្បទា ៖**<br>- កំណត់ប្រភេទរបាំខ្មែរទាំង៣ ប្រភពរបាំខ្មែរ តួនាទី និងការប្រើប្រាស់បានជាក់លាក់តាមរយៈខ្លឹមសារមេរៀន និងរូបភាព។<br>**បំណិនសម្បទា ៖**<br>- វែកញែកទម្រង់របាំនីមួយៗបានច្បាស់លាស់ និងអនុវត្តរាំរបាំប្រជាប្រិយជាក្រុមបានត្រឹមត្រូវគ្រប់ចង្វាក់តាមរយៈការបង្ហាញ និងដឹកនាំរបស់គ្រូ។<br>**ចរិយាសម្បទា ៖**<br>- មានភាពទន់ភ្លន់ សុភាពរាបសា មានសាមគ្គីភាពគ្នា និងស្រឡាញ់រាប់អានចំពោះអ្នកនៅជុំវិញខ្លួន ថែមទាំងចូលចិត្តរបាំខ្មែរកាន់តែខ្លាំង។ | ០៣ម៉ោងទ្រឹស្តី<br>០៦ ម៉ោងអនុវត្ត |
| **មេរៀនទី៤ ទម្រង់សិល្បៈល្ខោន**<br>៤.១- ការដឹកនាំរឿងល្ខោន<br>៤.១.១- វិធីសង្ខេបសាច់រឿង<br>៤.១.២- របៀបកាត់កងសាច់រឿង<br>៤.១.៣- របៀបកាត់កងឆាក<br>៤.១.៤- របៀបដឹកនាំការសំដែង<br>៤.២- ការអនុវត្តការសម្តែង<br><br>-សំណួរពិភាក្សា និងអនុវត្ត | **វិជ្ជាសម្បទា ៖**<br>- ពន្យល់ណែនាំទ្រឹស្តីនៃការដឹកនាំរឿងទម្រង់សិល្បៈល្ខោន<br>**បំណិនសម្បទា ៖**<br>- អនុវត្តរបៀបកាត់កងឆាក វិធីសង្ខេបរឿង និងបច្ចេកទេសដឹកនាំសម្តែងទម្រង់សិល្បៈល្ខោនបានត្រឹមត្រូវតាមក្បួនខ្នាតតាមរយៈការងារក្រុម<br>**ចរិយាសម្បទា ៖**<br>- ចូលរួមថែរក្សាបាននូវក្បួនខ្នាតទម្រង់សិល្បៈល្ខោនបែបខ្មែរនិយម។ | ០៣ម៉ោងទ្រឹស្តី<br>០៦ ម៉ោងអនុវត្ត |

| | | |
|---|---|---|
| **មេរៀនទី៥ តន្ត្រីខ្មែរ**<br>៥.១- តន្ត្រីបុរាណនៅក្នុងសង្គមខ្មែរ<br>៥.១.១- តន្ត្រី និងជំនឿ<br>៥.១.២- តន្ត្រី និងពិធីបុណ្យសាសនា<br>៥.១.៣- តន្ត្រី និងការកំសាន្ត<br>៥.១.៤- តន្ត្រី និងប្រពៃណីទំនៀមទម្លាប់<br>៥.២- ប្រភេទតន្ត្រីខ្មែរ<br>៥.២.១- វង់តន្ត្រីអារក្ស<br>៥.២.២- វង់តន្ត្រីការបុរាណ<br>៥.២.៣- វង់តន្ត្រីមហោរី<br>៥.២.៤- វង់តន្ត្រីពិណ្យពាទ្យ<br>៥.២.៥- វង់តន្ត្រី.អាយ៉ៃ<br>៥.២.៦- វង់តន្ត្រីឆៃយ៉ាំ<br>៥.២.៧- វង់តន្ត្រីស្គរឈ្នះ<br>៥.២.៨- វង់តន្ត្រីត្រៃលក្ខណ៍ឬទ្រាំមីង<br>៥.៣- ឧបករណ៍តន្ត្រីបុរាណខ្មែរ<br>៥.៣.១- ទ្រអ៊ូ<br>៥.៣.២- ទ្រខ្មែរ<br>៥.៣.៣- ខ្សែរដៀវ<br>៥.៣.៤- ចាប៉ីដងវែង<br>៥.៣.៥- ប៉ីអរ ឬប៉ីប្រប៉ុស<br>៥.៣.៦- ស្គរដៃ<br>-សំណួរពិភាក្សា និងអនុវត្ត | **វិជ្ជាសម្បទា ៖**<br>- រៀបរាប់បានច្បាស់លាស់ពីទម្រង់តន្ត្រីខ្មែរ ប្រភេទឧបករណ៍ភ្លេង  របៀបប្រើប្រាស់ របៀបប្រគំ តួនាទី និងសារៈសំខាន់នៃវង់ភ្លេងនីមួយៗតាមរយៈស្លាយមេរៀន ចម្រៀងនិងវីដេអូ។<br>**បំណិនសម្បទា ៖**<br>- អនុវត្តច្រៀងចម្រៀងគ្រប់ទម្រង់ និងបកស្រាយបាននូវតួនាទីរបស់វង់ភ្លេងនីមួយៗបានត្រឹមត្រូវតាមរយៈការងារក្រុម។<br>**ចរិយាសម្បទា ៖**<br>- មានចិត្តស្រឡាញ់ភ្លេងខ្មែរ ក៏ដូចជាសម្បត្តិវប្បធម៌ និងប្រទេសជាតិខ្លួន។ | ០៣ម៉ោងទ្រឹស្តី<br>០៦ ម៉ោងអនុវត្ត |

## ៨- ឯកសារយោង


១- កែវ ណារុំ (ឆ្នាំ ១៩៩៥) *តន្ត្រីនិងជីវិតខ្មែរ, ភ្នំពេញ*

២- កែវ ណារុំ (ឆ្នាំ២០០៥) *មរតកតន្ត្រីខ្មែរ, ភ្នំពេញ*

៣- ក្រុមស្រាវជ្រាវ ឆយ យីហ៊ាង(ឆ្នាំ ២០០៨) *ដំណើរវិវត្ត នៃអាពាហ៍ពិពាហ៍ខ្មែរ*

៤- ក្រុមសាស្ត្រាចារ្យស្រាវជ្រាវសាលាល្ខោន(ឆ្នាំ ២០០៤) *វិជ្ជាទូទៅជុំវិញសិល្បៈ, ភ្នំពេញ*

៥- ក្រុមសាស្ត្រាចារ្យស្រាវជ្រាវ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ(ឆ្នាំ២០០៣) *ឧបករណ៍តន្ត្រីបុរាណខ្មែរ, ភ្នំពេញ*

៦- ញ៉ែប សែ និងចក់ ឬទ្ធី(ឆ្នាំ ២០១០) *សៀវភៅកំណើតអប្សរា*

៧- គណៈកម្មការស្រាវជ្រាសិល្បៈវប្បធម៌(ឆ្នាំ ២០០៣) *ទស្សនីយភាពខ្មែរ ភ្នំពេញ*

៨- នួន កន (ឆ្នាំ ១៩៥៩) *កម្រងសិល្បៈសិក្សា, ភ្នំពេញ*

៩- ព្រះមហាសៅរ៍ ចន្ទថុល្ល (ឆ្នាំ ២០០២) *ភ្លេងពិណពាទ្យ ភ្លេងសៀម?*

១០- ពេជ្រ ទុំក្រវិល(ឆ្នាំ ២០០១) *របាំខ្មែរ,ភ្នំពេញ*

១១- ពេជ្រទុំ ក្រវិល(ឆ្នាំ ២០០៣) *សិល្បៈទស្សនីយភាពខ្មែរ, ភ្នំពេញ*

១២- ពេជ្រ ទុំក្រវិល (ឆ្នាំ ២០១០) *តន្ត្រី របាំ និងល្ខោនខ្មែរ, សាស្ត្រា, ភ្នំពេញ*

១៣- ម៉ៅ គឿង(ឆ្នាំ ២០០០) *ស្វែងយល់ជុំវិញសិល្បៈតន្ត្រីខ្មែរ*

១៤- សេង តារា(ឆ្នាំ ២០១២) *ការវិវត្តនៃតូរ្យតន្ត្រី*

១៥- សម្តេចព្រះសង្ឃរាជ ជួន ណាត *វចនានុក្រមខ្មែរ ភាគ១ ភាគ២* បោះពុម្ពលើកទី៥

១៦- ហ៊ុន សារិន (ឆ្នាំ ២០០៤) *វង់ភ្លេងខ្មែរ, ភ្នំពេញ*

១៧- ហ៊ុន សារិន(ឆ្នាំ ២០១១) *ស្វែងយល់សិល្បៈទស្សនីយភាពខ្មែរ។*

# វប្បធម៌

## ១- សេចក្តីផ្តើម

វប្បធម៌អរិយធម៌របស់ប្រទេសមួយរីកចម្រើនទៅបាន គេតែងកត់សម្គាល់ទៅលើបុគ្គលិកលក្ខណៈប្រជាពលរដ្ឋរបស់ប្រទេសនោះទាំងផ្នែកស្មារតី សម្ភារៈ ជីវភាពរស់នៅ ការងារសង្គម ការអភិវឌ្ឍក្រុមគ្រួសារសង្គមជាតិ ប្រពៃណីទំនៀមទម្លាប់...។ ហេតុនេះវប្បធម៌ អរិយធម៌នៃសង្គមនីមួយៗតែងមានលក្ខណៈពិសេសដោយឡែកៗពីគ្នា។ យ៉ាងណាមិញវប្បធម៌របស់ជនជាតិខ្មែរជាវប្បធម៌បុរាណមួយដែលត្រូវបានគេទទួលស្គាល់ក្នុងភូមិភាគអាស៊ីអគ្នេយ៍ថា មានការរីកចម្រើនដល់កំពូលនាសម័យកាលដ៏អស្ចារ្យមហានគរខ្មែរ ហើយធ្វើឱ្យយើងគ្រប់គ្នាមានមោទនភាពជាខ្លាំងជាមួយភាពជោគជ័យ រួមទាំងទិដ្ឋភាពគ្រប់យ៉ាងរបស់ខ្មែរនាសម័យនោះរហូតមកដល់បច្ចុប្បន្ន។ ប្រពៃណីទំនៀមទម្លាប់ខ្មែរធ្វើឱ្យខ្មែរក្លាយជាជនជាតិមួយដែលមានចរិកថ្លៃថ្នូរ ទន់ភ្លន់ តែម៉ឺងម៉ាត់។ តែសម័យក្រោយអង្គរ ខ្មែរបានផ្លាស់ប្តូរជាខ្លាំងក្រោមអំណាចនៃសង្គ្រាមបែកបាក់សាមគ្គីភាពប្រទេសជាតិ ប្រជាជាតិធ្លាក់ក្នុងភាពភ័យន្តរាយ វឹកវរ ជាបន្តបន្ទាប់ នោះហើយធ្វើឱ្យខ្មែរបាត់បង់អ្វីៗជារបស់ខ្លួនបន្តិចម្តងៗ ក្រោមការលុកលុយរបស់បរទេសពីមួយទៅមួយស្ទើរតែធ្វើឱ្យខ្មែរភ្លេចពីអត្តសញ្ញាណជាតិរបស់ខ្លួន ដែលជាហេតុធ្វើឱ្យអ្នកទស្សនវិទូជាច្រើនបានវែកញែកពីជាតិសាសន៍របស់ខ្មែរពិតប្រាកដ ។

ឆ្លងតាមការឆ្លុះបញ្ចាំងនូវចំណុចខាងលើជនជាតិខ្មែរគ្រប់រូប ត្រូវតែស្វែងយល់ពីអ្វីជាវប្បធម៌អរិយធម៌ខ្មែរឱ្យបានច្បាស់លាស់ទូលំទូលាយ និងប្រកាន់ខ្ជាប់គោលជំហររឹងមាំថា យើងជាខ្មែរពិតប្រាកដរស់នៅលើទឹកដីខ្មែរតាំងពីបុរេប្រវត្តិសាស្ត្រមកម្ល៉េះ។ ហេតុនេះឯកសារដ៏ស្តួចស្តើងខាងលើគ្រាន់តែជាកូនគំនិតសម្រាប់នាំផ្លូវអ្នកអានឱ្យស្រាវជ្រាវបន្ថែមទៀតនូវអ្វីដែលមានចម្ងល់តែប៉ុណ្ណោះ។ ម្យ៉ាងទៀតយើងត្រូវដឹងថាបើយើងឈ្លក់វង្វេងនឹងវប្បធម៌បរទេសហួសហេតុពេក នោះធ្វើឱ្យវប្បធម៌ខ្មែរនឹងត្រូវរលាយដូចពាក្យមួយថា "**វប្បធម៌រលត់ជាតិរលាយ វប្បធម៌ពណ្ណរាយជាតិថ្កើនថ្កាន**" ។ ហេតុនេះយើងជាកូនចៅជំនាន់ក្រោយត្រូវពួតដៃគ្នាថែរក្សានូវមរតកដូនតាដែលបានបន្សល់ទុកកុំឱ្យបាត់បង់ ព្រោះនេះជាព្រលឹងរបស់ជាតិខ្មែរ។

## ២- គោលបំណង

មុខវិជ្ជាវប្បធម៌នេះត្រូវបានអនុវត្តក្នុងការបណ្តុះបណ្តាលគរុនិស្សិតកម្រិតឧត្តម(បរិញ្ញាបត្រ+១) ដើម្បីក្លាយជាគ្រូជំនាញមានវិជ្ជាជីវៈ សីលធម៌មានប្រសិទ្ធិភាព និងការអភិវឌ្ឍប្រកបដោយនិរន្តភាព។

ដូច្នេះក្រោយពីការសិក្សានេះចប់អ្នកសិក្សានឹងអាចៈ

### ក- វិជ្ជាសម្បទា

- ពន្យល់បានពីវប្បធម៌ អរិយធម៌ខ្មែរ
- បង្ហាញពីចំណេះដឹងទូទៅដែលផ្សារភ្ជាប់នឹងផ្នែកវិធីសាស្ត្របង្រៀនរបស់អក្សរសាស្ត្រខ្មែរ
- សិក្សាច្បាស់លាស់នូវប្រេកពលក្ខណៈនៃវប្បធម៌ អរិយធម៌ខ្លួន គ្រប់ឥរិយាបទ ដេក ដើរ ឈរ អង្គុយ ទំនៀមទម្លាប់ប្រពៃណី ជំនឿសាសនា សិល្បៈ ... របស់ជាតិ។

### ខ- បំណិនសម្បទា

- ប្រើប្រាស់នូវពុទ្ធិវិទ្យាសាស្ត្រ បច្ចេកទេស បកស្រាយពីបញ្ហាសង្គម វប្បធម៌ បរិស្ថាន និងសេដ្ឋកិច្ចតាមរយៈអរិយធម៌
- អនុវត្តវិធីសាស្ត្របង្រៀនផ្សេងៗដោយយកសកម្មភាពជាកត្តាសំខាន់
- ដើម្បីបង្រៀនមុខវិជ្ជានេះប្រកបដោយប្រសិទ្ធភាព និងគុណភាព

- ច្នៃប្រឌិតនូវអ្វីៗដែលល្អ និងមានផលប្រយោជន៍ដល់សង្គមជាតិឱ្យប្រែក្លាយជារបស់ជាតិខ្លួន (ជាតូបនីយកម្ម) ស្របតាមដួងព្រលឹងជាតិ

- ផ្សារភ្ជាប់ចំណេះដឹងទូទៅស្ដីពីវប្បធម៌ជាតិ អន្តរជាតិ រួមជាមួយនឹងមុខវិជ្ជាឯកទេសផ្ទាល់ខ្លួន ដើម្បីលើកកម្ពស់គុណភាពអប់រំ តាមផែនការរបស់ជាតិ

- និយមប្រើប្រាស់នូវអ្វីៗដែលជារបស់ជាតិ និងផ្សព្វផ្សាយ ថែរក្សា ការពារ លើកតម្កើងនូវអ្វីៗដែលជារបស់ជាតិ។

**គ- ចរិយាសម្បទា**

- ស្រឡាញ់ថែរក្សាការពារអភិវឌ្ឍសង្គម វប្បធម៌ បរិស្ថាន និងសេដ្ឋកិច្ចខ្មែរ

- បណ្ដុះមនោសញ្ចេតនា ឱ្យចេះថែរក្សាការពារនូវអ្វីៗ ដែលជារបស់ជាតិ មរតកវប្បធម៌ជាតិ ពោលគឺវប្បធម៌ អរិយធម៌ដ៏រុងរឿងរបស់បុព្វបុរសដែលបានបន្សល់ទុកឱ្យ

- បំពេញកាតព្វកិច្ច និងស្វ័យអប់រំខ្លួនឱ្យក្លាយជាពលរដ្ឋល្អ មានមនសិការក្នុងបរេវិជ្ជាជីវៈតាមសម្មាជីវោ

- កំណត់ព្រំដែននៃសិទ្ធិ និងច្បាប់ ករណីកិច្ច និងការទទួលខុសត្រូវ ដើម្បីចៀសវាងការរំលោភសិទ្ធិទៅលើអ្នកដទៃ

- បង្កើតសាមគ្គីភាពល្អ ស្រឡាញ់យុត្តិធម៌ និងស្រឡាញ់មនុស្សជាតិទូទៅ

- រក្សាទំនាក់ទំនងល្អជាមួយជាតិ អន្តរជាតិ មិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ជំនឿ សាសនា។

**៣- គោលគំនិតសំខាន់ៗ**

- ចូលរួមផ្សព្វផ្សាយពីវប្បធម៌ អរិយធម៌ខ្មែរ

- បណ្ដុះគំនិតស្រឡាញ់ លើកស្ទួយ និងថែរក្សាវប្បធម៌ អរិយធម៌ខ្មែរ

- បញ្ជ្រាបគោលនយោបាយ អង្គការសហប្រជាជាតិស្ដីពីបម្រែបម្រួលអាកាសធាតុ(បរិស្ថាន វប្បធម៌)

- សមាហរណកម្មសហគមន៍អាស៊ាន

- បញ្ជ្រាបគោលនយោបាយសុខដុមនីយកម្មសាសនារបស់ព្រះរាជាណាចក្រកម្ពុជា

- កំណែទម្រង់កម្មវិធីសិក្សា។

**៤- របាយម៉ោងសិក្សា**

របាយម៉ោងសិក្សា នៃមុខវិជ្ជាវប្បធម៌ទូទៅ ត្រូវបានបែងចែកដូចក្នុងតារាងខាងក្រោម៖

| **មុខវិជ្ជា** | **រយៈពេលសិក្សា** |
|---|---|
| វប្បធម៌ទូទៅ | ១ ក្រេឌីត ស្មើ ១៥ ម៉ោងសិក្សា |

**៥- ការណែនាំអនុវត្ត**

ដើម្បីអនុវត្តការបង្រៀនលើមុខវិជ្ជានេះឱ្យបានជោគជ័យគ្រូបង្រៀនគប្បីត្រូវ៖

- ឱ្យអ្នកសិក្សាក្ដាប់បានពីចំណុចគន្លឹះសំខាន់ៗនៃមេរៀន តាមរយៈការប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការរៀននិងបង្រៀន ជំរុញការសិក្សាតាមបែបសកម្ម តាមរយៈការងារជាបុគ្គល ជាដៃគូ ជាក្រុម និងការស្រាវជ្រាវឯកសារជំនួយផ្សេងៗ។

- សម្របសម្រួលសិស្ស ក្នុងការក្ដាប់បាននូវខ្លឹមសារមេរៀន ដោយធ្វើការវិភាគស្ថានភាព និងការពិភាក្សារកដំណោះស្រាយ ដើម្បីទទួលបានទាំងចំណេះ ជំនាញ និងឥរិយាបថដែលសង្គមត្រូវការ។

## ៦- ការវាយតម្លៃ

ការវាយតម្លៃ គឺជាចំណុចសំខាន់ក្នុងការវាស់ស្ទង់ពីអ្វីដែលអ្នកសិក្សាទទួលបាន ធៀបទៅនឹងវត្ថុបំណង នៃមេរៀន ឬចំណុចអប្បរមានៃចំណេះដឹងរបស់អ្នកសិក្សាដែលគួរទទួលបានបន្ទាប់ពីបានបញ្ចប់ចំណុចនៃការសិក្សានីមួយៗ និងបញ្ចប់មុខវិជ្ជា។ ការវាយតម្លៃរួមមាន៖

-សំណួរផ្ទាល់មាត់

-កិច្ចការផ្ទះ

-កិច្ចការក្រុម

-ការឡើងធ្វើបទបង្ហាញ

- ការសួរសំណួរ ការពិភាក្សា ការប្រឡង និងការធ្វើគម្រោងស្រាវជ្រាវ ជាដើម។

## ៧- តារាងកម្មវិធីសិក្សាលម្អិត

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោងឱឥ |
|---|---|---|
| មេរៀនទី១<br>**វប្បធម៌ អរិយធម៌ខ្មែរ និងទំនាក់ទំនងវប្បធម៌ខ្មែរជាមួយបរទេស**<br>១.១-វប្បធម៌ខ្មែរ<br>១.១.១- និយមន័យ<br>១.១.២-លក្ខណៈពិសេសនៃវប្បធម៌<br>១.១.៣-មែកធាងវប្បធម៌<br>**១.២-សង្គមធម៌ខ្មែរ**<br>១.២.១- និយមន័យ<br>១.២.២- មែកធាងសង្គមធម៌<br>១.២.៣-ទំនាក់ទំនងរវាងវប្បធម៌ និងសង្គមធម៌<br>១.២.៤-ជាតុសំខាន់ៗដែលបង្កើតឱ្យមានវប្បធម៌ជាតិមួយ<br>**១.៣-អរិយធម៌ខ្មែរ**<br>១.៣.១- និយមន័យ<br>១.៣.២-មូលធម៌នៃអរិយធម៌<br>១.៣.៣-មែកធាងអរិយធម៌<br>**១.៤-ទំនាក់ទំនងវប្បធម៌ខ្មែរ ជាមួយបរទេស**<br>១.៤.១-អរិយធម៌ខ្មែរបុរាណ ឬអូស្ត្រូអាស៊ី | **វិជ្ជាសម្បទា**<br>-ប្រើប្រាស់អត្ថន័យបានត្រឹមត្រូវរបស់ពាក្យវប្បធម៌ សង្គមធម៌ អរិយធម៌។<br>-ពន្យល់បានពីអរិយធម៌បុរាណខ្មែរមុននឹងទទួលឥទ្ធិពលពីបរទេស។<br><br>**បំណិនសម្បទា ៖**<br>-វិភាគបានពីទំនាក់ទំនងរវាងវប្បធម៌ សង្គមធម៌ និងអរិយធម៌ និងផ្សារភ្ជាប់មែកធាងនីមួយៗមកក្នុងការរស់នៅប្រចាំថ្ងៃតាមរយៈលក្ខណៈពិសេសផ្សេងគ្នា។<br>-សិក្សាពីអ្វីជារបស់ខ្លួនច្បាស់ងាយប្រៀបធៀបបានពីទំនាក់ទំនងជាមួយបរទេស។<br><br>**ចរិយាសម្បទា**<br>-បណ្តុះស្មារតីស្រឡាញ់ ផ្សព្វផ្សាយ ថែរក្សាវប្បធម៌ អរិយធម៌ខ្មែរទៅឆាកអន្តរជាតិ ។<br>-បណ្តុះវប្បធម៌ចែករំលែកចំណេះដឹងទៅកាន់អ្នកជំនាន់ក្រោយ ដែលអាចសិក្សាពីគ្នាទៅវិញទៅមក។ | **២ពេល**<br>( **៣ម៉**) |

| | | |
|---|---|---|
| ១.៤.២- ឥទ្ធិពលវប្បធម៌បរទេសមកក្នុងសង្គមខ្មែរ | | |
| **មេរៀនទី២**<br>**របបមាតាធិបតេយ្យក្នុងសង្គមខ្មែរ**<br>២.១- និយមន័យ<br>២.២- ប្រភព និងស្ថានភាពរបបមាតាធិបតេយ្យ<br>២.៣-ឥទ្ធិពលរបបមាតាធិបតេយ្យក្នុងសង្គមខ្មែរ<br>២.៤-របបមាតាធិតេយ្យក្នុងជំនឿទំនៀមទម្លាប់ | **វិជ្ជាសម្បទា**<br>- ពន្យល់បានត្រឹមត្រូវនូវអត្ថន័យនៃពាក្យមាតាធិតេយ្យ។<br>**បំណិនសម្បទា**<br>-បកស្រាយបានពីប្រភព និងស្ថានភាពរបបមាតាធិបតេយ្យដែលមានទំនាក់ទំនង ទៅនឹងជំនឿ ទំនៀមទម្លាប់ក្នុងសង្គមខ្មែរ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីស្រឡាញ់ ផ្សព្វផ្សាយ ថែរក្សាទំនៀមទម្លាប់ប្រពៃណីខ្មែរតាមរយៈមាតាធិបតេយ្យកាន់តែប្រសើរឡើង ។ | **២ពេល**<br>(**៣ម៉**) |
| **មេរៀនទី៣**<br>**ឥទ្ធិពលសាសនាក្នុងសង្គមខ្មែរ**<br>៣.១-ជំនឿខ្មែរដើម<br>៣.២-ប្រភពនៃព្រាហ្មណ៍សាសនា<br>៣.៣-ប្រភពនៃសាសនាពុទ្ធសាសនា<br>៣.៤-ការវិវត្តនៃសាសនា<br>៣.៥-សិល្បៈស្ថាបត្យកម្មខ្មែរតាមទំនោរសាសនា | **វិជ្ជាសម្បទា**<br>-ពន្យល់បានពីជំនឿខ្មែរដើមនិងឥទ្ធិពលនៃសាសនាក្នុងសង្គមខ្មែរ ។<br>**បំណិនសម្បទា**<br>ប្រើប្រាស់អត្ថន័យត្រឹមត្រូវរយៈខ្លឹមសារសំខាន់នៃសាសនាក្នុងសង្គមខ្មែរទៅតាមដណាក់កាលនៃការវិវត្តសាសនា។<br>**ចរិយាសម្បទា** ៖ បណ្តុះស្មារតីគោរពប្រតិបត្តិស្រឡាញ់ ផ្សព្វផ្សាយ ថែរក្សាសាសនាក្នុងសង្គមខ្មែរកាន់តែប្រសើរឡើង ។ | **២ពេល**<br>(**៣ម៉**) |

| | | |
|---|---|---|
| មេរៀនទី៤ អត្តសញ្ញាណជាតិ និងទំនៀមទម្លាប់ប្រពៃណីខ្មែរ<br>៤.១-អត្តសញ្ញាណជាតិ និងព្រលឹងជាតិខ្មែរ<br>៤.២-ប្រពៃណី ទំនៀមទម្លាប់ | **វិជ្ជាសម្បទា ៖** ណែនាំអត្ថន័យពាក្យអត្តសញ្ញាណជាតិ និងព្រលឹងជាតិខ្មែរបានត្រឹមត្រូវ។<br>**បំណិនសម្បទា ៖**ពន្យល់បានពីខ្លឹមសារនៃអត្តសញ្ញាណ និងព្រលឹងជាតិខ្មែរ ប្រពៃណីទំនៀមទម្លាប់ផ្សេងៗក្នុងសង្គមខ្មែរ។<br>**ចរិយាសម្បទា ៖** បណ្តុះស្មារតី ស្រឡាញ់ លើកស្ទួយ ផ្សព្វផ្សាយ ថែរក្សាតម្លៃនៃអត្តសញ្ញាណ និងព្រលឹងជាតិក្នុងសង្គមខ្មែរកាន់តែប្រសើរឡើង ។ | **២ពេល**<br>(**៣ម៉**) |
| មេរៀនទី៥<br>**និមិត្តរូប និងលក្ខណៈពិសេសតំណាងប្រទេសកម្ពុជា**<br>៥.១- អត្តសញ្ញាណជាតិនៃកម្ពុជាក្នុងអាស៊ាន<br>៥.២-សម្បត្តិវប្បធម៌ខ្មែរចាត់ចូលបញ្ជីបេតិកភ័ណ្ឌពិភពលោក<br>( UNISCO ) | **វិជ្ជាសម្បទា**<br>- ពន្យល់បានពីអត្ថន័យនៃចំនុចសំខាន់អត្តសញ្ញាណជាតិក្នុងអាស៊ានទាក់ទងនឹងវប្បធម៌ខ្មែរ បានច្បាស់លាស់។<br>**បំណិនសម្បទា**<br>- បកស្រាយបានសម្បត្តិវប្បធម៌ជាតិដ៏មានតម្លៃនៅក្នុងប្រទេសកម្ពុជានៅក្នុងឆាកអន្តរជាតិ និងតាមរយៈការពិភាក្សាក្រុម ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតី ចូលរួមស្រឡាញ់ ផ្សព្វផ្សាយ ថែរក្សាអ្វីដែលជាតម្លៃរបស់ជាតិខ្មែរកាន់តែប្រសើរឡើង ។ | **២ពេល**<br>(**៣ម៉**) |

## ៨- ឯកសារយោង


១- ធ សោ *វប្បធម៌ អរិយធម៌* ភ្នំពេញ គ.ស១៩៥៤

២- ចាប ពិន *សាសនានិងទំនៀមទម្លាប់* ពុទ្ធសាសនបណ្ឌិត្យ ១៩៧០

៣- សែម សូរ *វប្បធម៌ អរិយធម៌ខ្មែរ-ឥណ្ឌា* គ.ស១៩៧១

៤- ត្រឹង ងា *អរិយធម៌ខ្មែរ* គ.ស១៩៧៤

៥- សរ សារុន *វប្បធម៌-អរិយធម៌* គ.ស១៩៧៤

៦- ផៃ សុខ *វប្បធម៌-អរិយធម៌ខ្មែរ-ឥណ្ឌា*

៧- កែប វ៉ាន់ឌី *វប្បធម៌-អរិយធម៌ខ្មែរ-មន* គ.ស១៩៧១

៨- ថាច់ វ៉ាន់ថាត និង កែវ សូកុង *វប្បធម៌ខ្មែរអាទិទេពក្រុងអង្គរ* គ.ស១៩៨៩
៩- លី ធាមតេង *ប្រពៃណីអ្នកស្រុកចេនឡា* គ.ស១៩៧៣
១០- ឈឹមក្រសេម *ព្រះរាជពិធីទ្វារទស្សមាស*
១១- ស៊ន សំណាង *ប្រវត្តិសាស្ត្រកម្ពុជា* រាជបណ្ឌិត្យសភាកម្ពុជា
១២- ឆត្រាប្រេម ឫឌី *ឯកសារនគរគោកធ្លក* គ.ស១៩៧៣
១៣- កិច្ចការស្រាវជ្រាវគរុនិស្សិតជីវវិទ្យា *សម្លៀកបំពាក់ខ្មែរ ក្នុងអាស៊ាន* គ.ស២០១៥
១៤- កិច្ចការស្រាវជ្រាវគរុនិស្សិត *សំណង់ស្ថាបត្យកម្ម ក្នុងអាស៊ាន* គ.ស២០១៥
១៥- កិច្ចការស្រាវជ្រាវគរុនិស្សិត *មុខម្ហូប ក្នុងអាស៊ាន* គ.ស២០១៥
១៦- កិច្ចការស្រាវជ្រាវគរុនិស្សិត *សត្វលើគោក ក្នុងអាស៊ាន* គ.ស២០១៥
១៧- កិច្ចការស្រាវជ្រាវគរុនិស្សិត *រុក្ខជាតិ ក្នុងអាស៊ាន* គ.ស២០១៥
១៨- កិច្ចការស្រាវជ្រាវគរុនិស្សិត *សត្វក្នុងទឹក ក្នុងអាស៊ាន* គ.ស២០១៥
១៩- កិច្ចការស្រាវជ្រាវគរុនិស្សិត *បុប្ផា(ផ្កា) ក្នុងអាស៊ាន* គ.ស២០១៥
២០- កិច្ចការស្រាវជ្រាវគរុនិស្សិត *សត្វលើអាកាស ក្នុងអាស៊ាន* គ.ស២០១៥
២១- កិច្ចការស្រាវជ្រាវគរុនិស្សិត *បុគ្គលសំខាន់ ក្នុងអាស៊ាន* គ.ស២០១៥
២២- កិច្ចការស្រាវជ្រាវគរុនិស្សិត *ទង់ជាតិ ក្នុងអាស៊ាន* គ.ស២០១៥
២៣- កិច្ចការស្រាវជ្រាវគរុនិស្សិត *សិល្បៈ និងវប្បធម៌ ក្នុងអាស៊ាន* គ.ស២០១៥
២៤- កិច្ចការស្រាវជ្រាវគរុនិស្សិត ក្នុងអាស៊ាន គ.ស២០១៥
២៥- កិច្ចការស្រាវជ្រាវគរុនិស្សិតអក្សរសាស្ត្រខ្មែរ *សម្បត្តិវប្បធម៌ខ្មែរ ក្នុងអាស៊ាន* គ.ស២០១៥
២៦- កិច្ចការស្រាវជ្រាវគរុនិស្សិត *សម្លៀកបំពាក់ខ្មែរ ក្នុងអាស៊ាន* គ.ស២០១៥
២៧- កិច្ចការស្រាវជ្រាវគរុនិស្សិតភាសាអង់គ្លេស *ពិធីបុណ្យសមុទ្រ* គ.ស២០១៦

# ប្រឹក្សាគរុកោសល្យ

## ១- សេចក្តីផ្តើម

គ្រូបង្រៀនជាកតាលីករដ៏ចាំបាច់ និងមិនអាចខ្វះបានក្នុងការចូលរួមចំណែកលើកកម្ពស់គុណភាពអប់រំ។ សម្រាប់បរិការសតវត្សទី២១នេះ គ្រូបង្រៀនទាមទារឱ្យមានសមត្ថភាព ចំណេះដឹងឯកទេសទូលំទូលាយ បំណិនវិជ្ជាជីវៈច្បាស់លាស់ ក្រមសីលធម៌វិជ្ជាជីវៈ បច្ចេកវិទ្យាព័ត៌មាន ភាសាបរទេស វិធីសាស្ត្របង្រៀនសំបូរបែប និងសិល្បៈក្នុងការបង្រៀនផ្សេងៗទៀត ដើម្បីជំរុញការសិក្សាតាមបែបសកម្មទាំងក្នុងនិងនៅក្រៅថ្នាក់រៀន។ តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថាគ្រូបង្រៀន ជាពិសេសគ្រូទើបនឹងចេញថ្មី ត្រូវការអ្នកជួយគាំទ្របន្ថែម ទាំងផ្នែកជំនាញឯកទេស វិធីសាស្ត្របង្រៀន ការគ្រប់គ្រងថ្នាក់រៀន ផ្នែកបច្ចេកទេស និងផ្នែកសតិអារម្មណ៍ដើម្បីដឹកនាំការបង្រៀន និងរៀនឱ្យទទួលបាននូវប្រសិទ្ធភាពខ្ពស់។ ការអនុវត្តប្រព័ន្ធនៃការប្រឹក្សាគរុកោសល្យ អាចជួយគ្រូបង្រៀនក្នុងការដោះស្រាយបញ្ហាប្រឈមនានាដែលកើតឡើងក្នុងការបង្ហាត់បង្រៀនរបស់ពួកគាត់ និងអាចជួយគាំទ្រគ្រូបង្រៀនដទៃទៀតផងដែរ។

មុខវិជ្ជាប្រឹក្សាគរុកោសល្យនៅថ្នាក់បរិញ្ញាបត្រ+២នេះ ពិតជាមានសារៈសំខាន់ និងជារឿងអាទិភាពមួយដែលអាចជួយគាំទ្រគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) ទៅលើជំនាញប្រឹក្សាគរុកោសល្យ និងគាំទ្រយ៉ាងសកម្មក្នុងដំណើរការមុន និងក្រោយពេលនៃការចុះកម្មសិក្សាប្រតិបត្តិរបស់គរុនិស្សិត ដើម្បីត្រៀមខ្លួនរួចជាស្រេចក្នុងវិជ្ជាជីវៈជាគ្រូបង្រៀនប្រកបដោយគុណភាព និងបំណិនពេញលេញ ពេលបញ្ចប់ការសិក្សាដោយជោគជ័យពីវិទ្យាស្ថានជាតិអប់រំ។

## ២- គោលបំណង

### ក- វិជ្ជាសម្បទា

- រៀបរាប់បានពីគោលការណ៍ទូទៅនៃការប្រឹក្សាគរុកោសល្យ សារៈសំខាន់ និងបញ្ហាប្រឈមនានាក្នុងប្រព័ន្ធប្រឹក្សាគរុកោសល្យតាមសាលារៀន
- ចេះពន្យល់បកស្រាយ ចែករំលែក និងផ្តល់មតិកែលម្អទៅលើការរៀបចំផែនការបង្រៀន សម្រាប់យកទៅបង្រៀន
- អាចវិភាគពីចំណុចល្អ និងចំណុចគួរអភិវឌ្ឍបន្ថែមដោយសមហេតុផលនៅក្នុងការបង្រៀនណាមួយដោយខ្លួនឯងឬការបង្រៀនរបស់លោកគ្រូ អ្នកគ្រូផ្សេង
- មានសមត្ថភាពក្នុងការអង្កេតថ្នាក់រៀនបានគ្រប់ជ្រុងជ្រោយ និងការសិក្សាស្រាវជ្រាវមេរៀន (Lesson Study)

### ខ- បំណិនសម្បទា

- អនុវត្តវដ្តនៃការប្រឹក្សាគរុកោសល្យបានប្រកបដោយវិជ្ជាជីវៈ (Mentoring Cycle Reflection) តាមសាលារៀន
- បំពេញការងារចុះកម្មសិក្សាគរុកោសល្យបានយ៉ាងមានប្រសិទ្ធភាពខ្ពស់
- មានជំនាញបង្រៀនច្បាស់លាស់
- អនុវត្តបំណិនអង្កេតថ្នាក់រៀនដោយផ្ទាល់ និងតាមវីដេអូបង្រៀន បានគ្រប់ជ្រុងជ្រោយ និងច្បាស់លាស់
- មានគំនិតច្នៃប្រឌិត និងភាពបត់បែន ក្នុងការដោះស្រាយបញ្ហានានា

**គ- ចរិយាសម្បទា**

- បណ្តុះគំនិត និងស្មារតី ឱ្យគរុនិស្សិតចេះធ្វើការជាក្រុម ចេះរៀបចំការផ្តល់ប្រឹក្សាគរុកោសល្យក្នុងក្រុមរបស់គាត់ អំឡុងពេលចុះកម្មសិក្សាប្រតិបត្តិ
- បណ្តុះស្មារតីក្នុងភាពជាអ្នកដឹកនាំ គ្រប់គ្រងអប់រំ
- ស្រឡាញ់ពេញចិត្តវិជ្ជាជីវៈជាគ្រូបង្រៀន ដោយប្រកាន់នូវវប្បធម៌ចែករំលែក គាំទ្រ និងជួយគ្រូបង្រៀនដទៃទៀតក្នុងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ។

## ៣- គោលគំនិតសំខាន់ៗ

ក្នុងមុខវិជ្ជាប្រឹក្សាគរុកោសល្យសម្រាប់ថ្នាក់បរិញ្ញាបត្រ+២នេះ រួមមានពីរជំពូក ដែលជំពូកទី១ផ្តោតទៅលើការសិក្សាទ្រឹស្តីអំពីគោលការណ៍ទូទៅនៃការប្រឹក្សាគរុកោសល្យ និងជំពូកទី២ ផ្តោតលើការអនុវត្តការប្រឹក្សាគរុកោសល្យផ្ទាល់នៅក្នុងថ្នាក់ និងក្នុងក្លឹបសិក្សាមុនពេលចុះកម្មសិក្សាប្រតិបត្តិ។

**ជំពូកទី១៖ ការសិក្សាទ្រឹស្តីអំពីគោលការណ៍ទូទៅនៃការប្រឹក្សាគរុកោសល្យ**

ក្នុងជំពូកនេះនឹងផ្តោតសំខាន់ទៅលើខ្លឹមសារគោលមួយចំនួនដែលទាក់ទងនឹងគោលការណ៍ទូទៅនៃការប្រឹក្សាគរុកោសល្យរួមមានដូចជា៖ តើការប្រឹក្សាគរុកោសល្យជាអ្វី? តួនាទី នៃអ្នកប្រឹក្សាគរុកោសល្យ ប្រភេទនៃការប្រឹក្សាគរុកោសល្យ សារៈសំខាន់នៃការប្រឹក្សាគរុកោសល្យ ក្រមសីលធម៌វិជ្ជាជីវៈអ្នកប្រឹក្សាគរុកោសល្យ បញ្ហាប្រឈមនៃការប្រឹក្សាគរុកោសល្យ និងការអង្កេតថ្នាក់រៀនផ្តោតលើបំណិននៃការប្រឹក្សាគរុកោសល្យជាដើម។

**ជំពូកទី២៖ ការអនុវត្តការប្រឹក្សាគរុកោសល្យផ្ទាល់ក្នុងថ្នាក់រៀន និងក្លឹបសិក្សា**

ក្នុងជំពូកនេះជាការសិក្សាស្ថិតក្រោមរូបភាពនៃការអនុវត្តការប្រឹក្សាគរុកោសល្យជាក់ស្តែងបន្ទាប់ពីបានសិក្សាទ្រឹស្តីរួចមក ហើយនិស្សិតត្រូវចូលរួមក្នុងក្លឹបសិក្សា ដើម្បីមានឱកាសបានចូលរួមប្រឹក្សាយោបល់ ផ្តល់មតិត្រឡប់ សិក្សាពីចំណុចខ្លាំង ចំណុចដែលគួរអភិវឌ្ឍបន្ថែមពីគ្នាទៅវិញទៅមក សិក្សាពីវដ្តនៃការប្រឹក្សាគរុកោសល្យនិងសិក្សាពីគន្លឹះសំខាន់ៗក្នុងការគាំទ្រផ្សេងៗ ក្នុងការប្រឹក្សាគរុកោសល្យប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីជាដំណោះស្រាយត្រៀមទុកជាមុនសម្រាប់ការចុះកម្មសិក្សាប្រតិបត្តិគរុកោសល្យ និងត្រៀមលក្ខណៈរួចជាស្រេចពេលចេញទៅបង្រៀនក្រោយបញ្ចប់ការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ។

## ៤- របាយម៉ោងសិក្សា

របាយម៉ោងសិក្សានៃមុខវិជ្ជាប្រឹក្សាគរុកោសល្យ ត្រូវបានបែងចែកដូចក្នុងតារាងខាងក្រោម៖

| មុខវិជ្ជា | រយៈពេលសិក្សា |
|---|---|
| **ប្រឹក្សាគរុកោសល្យ** | ២ ក្រេឌីត ស្មើ ៣០ ម៉ោងសិក្សា |

## ៥- ការណែនាំការអនុវត្ត

ដើម្បីអនុវត្តការបង្រៀនលើមុខវិជ្ជានេះ ឱ្យបានជោគជ័យគ្រូប្រឹក្សាគរុកោសល្យគប្បី៖

- សម្របសម្រួលគរុនិស្សិតឱ្យក្តាប់បានពីចំណុចគន្លឹះសំខាន់ៗនៃមេរៀន ដោយប្រើគោលវិធីសិស្សមជ្ឈមណ្ឌល និងវិធីសាស្ត្រថ្មីៗក្នុងការបង្រៀនដូចជា៖ ការរៀនតាមបែបសិក្ខាសាលា (Seminar Style) ការសិក្សាស្រាវជ្រាវមេរៀន (Lesson Study) ការសិក្សាតាមបែបរិះរក (Inquiry Based Learning) និងការសិក្សាបែបចម្រុះ (Blended Learning) ជាដើម

- ជំរុញការសិក្សាបែបសកម្មតាមរយៈការងារជាបុគ្គល ជាដៃគូ ជាក្រុម និងការស្រាវជ្រាវលើឯកសារជំនួយផ្សេងៗ

- ដឹកនាំនិងរៀបចំកិច្ចការស្រាវជ្រាវទាក់ទងទៅនឹងមេរៀនផ្សេងៗ ដើម្បីផ្តល់ឱកាសឱ្យគរុនិស្សិតក្តាប់បាននូវខ្លឹមសារមេរៀនដោយចេះវិភាគលើស្ថានភាព ស្វែងរកដំណោះស្រាយ និងធ្វើការជាក្រុម ឆ្ពោះទៅរកចំណេះដឹង សមត្ថភាព ជំនាញ និងឥរិយាបថល្អដែលសង្គមត្រូវការ ហើយស្របទៅតាមគោលដៅកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ។

## ៦- ការវាយតម្លៃ

ការវាយតម្លៃ គឺជាចំណុចសំខាន់ ក្នុងការវាស់ស្ទង់ពីអ្វីដែលគរុនិស្សិតទទួលបាន ធៀបទៅនឹងវត្ថុបំណងនៃមេរៀន ឬចំណុចអប្បរមានៃចំណេះដឹងរបស់អ្នកសិក្សាដែលគួរទទួលបាន បន្ទាប់ពីបានបញ្ចប់ចំណុចនៃការសិក្សានីមួយៗនិងបញ្ចប់មុខវិជ្ជាប្រឹក្សាគរុកោសល្យនេះ។

- វត្តមាន (១០%)
- ការចូលរួមសកម្មភាពក្នុងថ្នាក់ និងការឡើងធ្វើបទបង្ហាញគម្រោងស្រាវជ្រាវ (១០%)
- ការសង្ខេបមេរៀននិងការឆ្លុះបញ្ចាំង (២០%)
- ប្រឡងត្រួតពិនិត្យសមត្ថភាពពាក់កណ្តាលឆមាស (២៥%)
- ការប្រឡងបញ្ចប់ឆមាស (៣៥%)។

## ៧- តារាងកម្មវិធីសិក្សាលម្អិត

| ខ្លឹមសារ | លទ្ធផលសិក្សារំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូកទី១៖ គោលការណ៍ទូទៅនៃការប្រឹក្សាគរុកោសល្យ** | | |
